# ធនាគារជាតិ នៃ កម្ពុជា




# របាយការណ៍ប្រចាំឆ្នាំ
# ២០០៧

## នាយកដ្ឋានត្រួតពិនិត្យ

# អារម្ភកថា



រយៈពេល១០ឆ្នាំបានកន្លងទៅ បន្ទាប់ពីមានវិបត្តិហិរញ្ញវត្ថុនៅអាស៊ីនាឆ្នាំ ១៩៩៧ ខណៈដែលវិបត្តិនេះបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះបណ្តាប្រទេសនៅអាស៊ី ប្រទេសកម្ពុជាបានទទួលរងផលប៉ះពាល់តិចតួច ដោយសារតែកត្តាសំខាន់ៗចំនួនបី ។ កត្តាទីមួយ ប្រព័ន្ធធនាគារនៅក្នុងប្រទេសកម្ពុជានាពេលនោះស្ថិតនៅ ក្នុងដំណាក់កាលចាប់ផ្តើម និងទន់ខ្សោយ ក៏រិតអន្តរការិយកម្មធនាគារនិងហិរញ្ញវត្ថុនៅមានកំរិតទាប និងមិនទាន់ស៊ីជម្រៅ ពុំទាន់មានទីផ្សារហិរញ្ញវត្ថុ ដូច្នេះក៏ពុំទាន់មានលំហូរចេញដ៏ឆាប់រហ័សនៃមូលធនដែលបានយកមកវិនិយោគរយៈពេលខ្លីលើមូលបត្រ ។ កត្តាទីពីរ កម្ពុជាមានសេដ្ឋកិច្ចដុល្លារូបនីយកម្មខ្ពស់ ប្រតិបត្តិការអន្តរការិយកម្មធនាគារស្ទើរតែ ១០០% បានប្រព្រឹត្តទៅជាប្រាក់រូបិយប័ណ្ណ ដែលជារបាំងពុំឱ្យមានហានិភ័យនៃការប្តូរប្រាក់ ជាហេតុនាំឱ្យវិនិយោគិនពុំមានការព្រួយបារម្ភ ពីការធ្លាក់ចុះតម្លៃនៃទ្រព្យសកម្មរបស់គេដោយសារតែហានិភ័យនៃអត្រាប្តូរប្រាក់នោះ ។ កត្តាទី៣ ភាពលើសលុបនៃលំហូរមូលធនតាមរយៈការវិនិយោគផ្ទាល់ពីបរទេស ជាការគាំទ្របន្ថែមក្នុងស្ថិរភាពសេដ្ឋកិច្ច ។

បន្ទាប់ពីច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវបានប្រកាសឱ្យប្រើនៅចុងឆ្នាំ ១៩៩៩ កំណែទំរង់ប្រព័ន្ធធនាគារទាំងមូលត្រូវបានចាប់ផ្តើមអនុវត្តចាប់ពីឆ្នាំ ២០០០ មក ដោយផ្តោតទៅលើការពង្រឹងមូលដ្ឋានដើមទុនអប្បបរមាពី ៥ លានដុល្លារអាមេរិក ទៅ ១៣ លានដុល្លារអាមេរិក ការសំគាល់អត្តសញ្ញាណច្បាស់លាស់នៃភាគទុនិក ការគ្រប់គ្រងគ្រឹះស្ថានឱ្យគោរពតាមច្បាប់ និងបទបញ្ញាប្រុងប្រយ័ត្ននានាដែលបានដាក់ចេញ ។ ក្នុងន័យនេះបទបញ្ញាប្រុងប្រយ័ត្នថ្មីៗត្រូវបានដាក់ចេញ និងកែលំអជាបន្តបន្ទាប់ ដើម្បីឱ្យទាន់សភាពការនៃការវិវឌ្ឍនដ៏លឿននៃប្រព័ន្ធធនាគារ ចាប់ពីពេលចាប់ផ្តើមធ្វើកំណែទំរង់ រហូតមកដល់ពេលបច្ចុប្បន្ននេះ ។ តាមរយៈការខិតខំប្រឹងប្រែងដ៏ស្វិតស្វាញរបស់អាជ្ញាធរត្រួតពិនិត្យ និងកិច្ចសហការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងការប្រតិបត្តិតាមយ៉ាងម៉ឺងម៉ាត់នូវរាល់ច្បាប់ ប្រកាស សេចក្តីណែនាំនានាមក ប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុកម្ពុជាបច្ចុប្បន្ន បានឈានដល់ដំណាក់កាលរឹងមាំ មានលទ្ធភាពពង្រីកបណ្តាញសេវា ហើយនិងការបង្កើតផលិតផលថ្មី ដូចជាម៉ាស៊ីនអេធីអឹម (ATM) ប័ណ្ណឥណពន្ធ ប័ណ្ណឥណទាន សេវាប្រតិបត្តិការធនាគារតាមអ៊ីនធឺណែត (Internet Banking) និងតាមទូរស័ព្ទចល័ត (Mobile Banking) ជាដើម ។

នៅក្នុងឆ្នាំ២០០៧ ប្រាក់បញ្ញើ និងឥណទានមានប្រហែល ១០ពាន់ ពាន់លានរៀល ( ស្មើនឹង ២,៥ពាន់ លានដុល្លារអាមេរិក) និង ៦,២ពាន់ ពាន់លានរៀល ( ស្មើនឹង ១,៥ពាន់ លានដុល្លារអាមេរិក ) ដែលជាកំណត់ត្រានៃកំណើន ៧៤,៥% និង ៧៧% រៀងគ្នា បើប្រៀបធៀបទៅនឹងឆ្នាំ ២០០៦ ។ កំណើនយ៉ាងខ្លាំងនេះបានឆ្លុះបញ្ចាំងឱ្យឃើញពីភាពប្រសើរជាងមុននៃជំនឿទុកចិត្តនៅក្នុងប្រព័ន្ធធនាគារ និងតួនាទីជាអន្តរការីយកម្មនៅក្នុងប្រទេសកម្ពុជា ។ ស្របពេលដែលសេដ្ឋកិច្ចជាតិមានការកើនឡើង ការផ្តល់ឥណទានខាងសំណង់មានការកើនឡើងច្រើនជាងឆ្នាំមុនលើសពីរដង ។ កំណើនឥណទានយ៉ាងខ្លាំង និងការធ្វើឱ្យកាន់តែប្រសើរនូវគោលនយោបាយប្រុងប្រយ័ត្នបានធ្វើឱ្យអនុបាតឥណទានមិនដំណើរការមានការថយចុះពី ៩,៨% មក ៣,៤% ។ វិស័យមីក្រូហិរញ្ញវត្ថុ មានសន្ទុះកើនឡើងជាមួយនឹងកំណើនឥណទាន ៧៣% បើប្រៀបធៀបទៅនឹងឆ្នាំ ២០០៦ ហើយ ជាមួយនឹងកំណើន៣២,៥%នៃចំនួនអ្នកខ្ចីពី ៤៧១.០២៦ នាក់ ទៅ ៦២៤.០៨៩ នាក់ ។ នៅក្នុងខែវិច្ឆិកា ធនាគារជាតិនៃកម្ពុជា សហការជាមួយនឹងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) និងធនាគារអេ អ៊ិន ហ្សេត រ៉ូយ៉ាល់ បានរៀបចំសន្និសីទមីក្រូហិរញ្ញវត្ថុស្តីពី ***ជំហានថ្មីឆ្ពោះទៅមុខ: ការលុបបំបាត់ចោលរបាំងរវាងមីក្រូហិរញ្ញវត្ថុ និង វិស័យធនាគារផ្លូវការ*** ដែលមានការចូលរួមពីសំណាក់មន្ត្រីរាជរដ្ឋាភិបាល មន្ត្រីធនាគារជាតិនៃកម្ពុជា ម្ចាស់ជំនួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារ ក្នុងប្រទេស និងអ្នកវិនិយោគអន្តរជាតិ ក្នុងគោលបំណងបង្កើនលទ្ធភាពទទួលបានមូលនិធិក្នុងតម្លៃទាបពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរបស់ប្រជាកសិករ ។ សន្និសីទនេះ ក៏មានបំណងជំរុញឱ្យវិនិយោគិនស្វែងយល់កាន់តែច្បាស់ ពិសេសជាងនេះទៅទៀត ជំរុញដល់ធនាគារក្នុងស្រុកលើសក្តានុពលភាពនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅប្រទេសកម្ពុជា ។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសថ្មីមួយ ដែលអនុញ្ញាតឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនដែលមានស្ថានភាពរឹងមាំ អាចទទួលប្រាក់បញ្ញើពីសាធារណជន ។ ទោះបីជាមានការរីកចម្រើនយ៉ាងណាក៏ដោយ ក៏សក្តានុពលនៃហានិភ័យមានការកើនឡើងដែរ ។

ថ្មីៗនេះការកើនឡើងជាគំហុកនៃតម្លៃអចលនទ្រព្យ គឺជាបញ្ហាមួយដែលធ្វើឱ្យមន្ត្រីត្រួតពិនិត្យមានការព្រួយបារម្ភជាពិសេសការតាមដានតម្លៃទ្រព្យសកម្ម ។ ការវិនិយោគលើដីធ្លី និងអចលនទ្រព្យ កើតឡើងក្នុងចំណោមអ្នកមាន និងអ្នកថ្នាក់មធ្យមនៅក្នុងប្រទេសកម្ពុជា នៅទីក្រុងសំខាន់ៗ ។ ទោះបីជាមានទស្សនៈថាការវិនិយោគផ្ទាល់ពីបរទេសនៅប្រទេសកម្ពុជាបានការកើនឡើងពី ៤៨៣,២ លានដុល្លារអាមេរិក ដល់ ៨៦៧,៣ លានដុល្លារអាមេរិក នៅឆ្នាំ ២០០៧ ហើយនេះជាកំណើនសមល្មមយ៉ាងណាក៏ដោយ ក៏ការកើនឡើងយ៉ាងខ្ពស់នៃតម្លៃអចលនទ្រព្យ គឺវាឆាប់រហ័សពេកក្នុងការធ្វើនិយ័តកម្ម ។ វិបត្តិនៃតម្លៃអចលនទ្រព្យនឹងអាចកើតឡើង ដូចដែលធ្លាប់កើតមានឡើងនៅបណ្តាប្រទេសជិតខាងយើងកាលពីដប់ឆ្នាំកន្លងទៅ ។ ហេតុដូចនេះការសង្កេតតាមដានត្រូវមានភាពប្រយ័ត្នជាពិសេសលើឥណទានដែលមានដាក់អចលនទ្រព្យជាវត្ថុធានា ។ តម្រូវការក្នុងការត្រួតពិនិត្យយ៉ាងជិតដល់លើកម្ចីទៅឱ្យវិស័យនេះដែលដឹងច្បាស់ថា មានហានិភ័យ គឺមានសារៈសំខាន់ណាស់ក្នុងការការពារនូវការកើតមានវិបត្តិ ។ម្យ៉ាងទៀតការខិតខំប្រឹងប្រែងនេះគឺ ដើម្បីធានា

ថាធនាគារចាត់ថ្នាក់ឥណទានបានត្រឹមត្រូវតាមប្រភេទជំនួញ ដើម្បីបញ្ជាក់ថាធនាគារមិនបានបង្កើតឡើងនូវភាពមិនស្មើគ្នានៃសំណុំហានិភ័យឥណទាន ។

ដើម្បីគ្រប់គ្រងសន្ទុះការរីកចម្រើនយ៉ាងខ្លាំងនៃបរិដ្ឋានហិរញ្ញវត្ថុនេះ ធនាគារជាតិនៃកម្ពុជាបន្តពង្រឹងសមត្ថភាពមន្ត្រីត្រួតពិនិត្យតាមរយៈការបណ្តុះបណ្តាលក្នុងពេលធ្វើការងារ និងការបណ្តុះបណ្តាលនៅក្នុងស្រុក និង នៅបរទេស ។ បទបញ្ញត្តិត្រូវបានកែសម្រួលឡើងវិញ និងធ្វើបច្ចុប្បន្នកម្ម ។ ការត្រួតពិនិត្យឱ្យបានជិតដល់ជាមួយនឹងវិធានការណ៍កែតម្រូវជាបន្ទាន់ និងតម្លាភាព គឺជាគន្លឹះមួយដែលនាំឱ្យប្រព័ន្ធធនាគារមានភាពរឹងមាំ និងមានសុវត្ថិភាព ។

ខ្ញុំសង្ឃឹមថារបាយការណ៍នេះនឹងបម្រើប្រយោជន៍មិត្តអ្នកអានឱ្យស្វែងយល់ស៊ីជម្រៅ និងកាន់តែប្រសើរពីប្រព័ន្ធធនាគារនៅក្នុងប្រទេសកម្ពុជា។

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០០៨

**ជា ចាន់តូ**

**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**

# មាតិកា


**ទំព័រ**

**អារម្ភកថា** ........ i

**មាតិកា** ........ iv

**តារាងរូបភាព** ........ vi

**តារាងអក្សរកាត់** ........ vii

**១.	ការប្រព្រឹត្តិទៅនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ** ........ **១**

១.១-	រចនាសម្ព័ន្ធតារាងតុល្យការគ្រឹះស្ថានធនាគារ ........ ២

១.២-	ឥណទាន និង ប្រាក់បញ្ញើគ្រឹះស្ថានធនាគារ ........ ៣

១.៣-	អនុបាតប្រុងប្រយ័ត្ន ........ ៥

១.៤-	រចនាសម្ព័ន្ធតារាងតុល្យការនិងការអភិវឌ្ឍន៍វិស័យមីក្រូហិរញ្ញវត្ថុ ........ ៧

- ឥណទាន និងប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ........ ៧
- អនុបាតប្រុងប្រយ័ត្ន ........ ៨

**២.	ការប្រឈមមុខមួយចំនួនរបស់វិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា** ........ **១១**

២.១-	កំណើនយ៉ាងឆាប់រហ័សនៃទីផ្សារអចលនទ្រព្យនៅកម្ពុជា ........ ១១

២.២-	ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ........ ១១

២.៣-	អភិបាលកិច្ច ........ ១១

២.៤-	ការត្រួតពិនិត្យផ្អែកលើហានិភ័យ ........ ១២

២.៥-	ប្រតិបត្តិការធនាគារដោយប្រើអេឡិចត្រូនិក ........ ១២

២.៦-	ការពង្រឹងសមត្ថភាពមន្ត្រីនាយកដ្ឋានត្រួតពិនិត្យ ........ ១២

២.៧-	កាធ្វើវិសោធនកម្មនិងចេញបទបញ្ជាសម្រាប់ការត្រួតពិនិត្យ ឆ្នាំ២០០៧ ........ ១៣

**៣.	ស្ថានភាពការប្រឆាំងការសំអាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម** ........ **១៤**

៣.១-	ទិដ្ឋភាពទូទៅ ........ ១៤

៣.២-	ច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ........ ១៤

៣.៣-	អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ (FIU) ........ ១៤

៣.៤-	ការវាយតម្លៃអញ្ញមញ្ញ (Mutual Evaluation) ........ ១៤

៣.៥-	ជំនួយបច្ចេកទេស: ........ ១៥

៣.៦- ទិសដៅអាទិភាពៈ ........................................................................................................ ១៥
**ឧបសម្ព័ន្ធទី១: រចនាសម្ព័ន្ធនាយកដ្ឋានត្រួតពិនិត្យ............................................................................១៦**
**ឧបសម្ព័ន្ធទី២: ទិន្នន័យគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឆ្នាំ ២០០៧............................១៧**
**ឧបសម្ព័ន្ធទី៣: អត្រាការប្រាក់.........................................................................................................១៨**
**ឧបសម្ព័ន្ធទី៤: ប្រព័ន្ធធនាគារនៅកម្ពុជា ......................................................................................... ២០**
**ឧបសម្ព័ន្ធទី៥: គោលការណ៍គ្រឹះបាសែលទាំង២៥ ............................................................................. ២៣**
**ឧបសម្ព័ន្ធទី៦: ប្រតិបត្តិការធនាគារដោយអេឡិចត្រូនិក..................................................................... ៣៣**

# តារាងរូបភាព


រូបភាពទី ១: ចំនួនអ្នកដាក់ប្រាក់បញ្ញើ និងអ្នកខ្ចីប្រាក់......១
រូបភាពទី ២: ទ្រព្យសកម្មសរុប និងផលិតផលក្នុងស្រុកដុល......២
រូបភាពទី ៣: សមាសភាពទ្រព្យសកម្ម និង ទ្រព្យអកម្ម......៣
រូបភាពទី ៤: សមាសភាពប្រាក់បញ្ញើរបស់អតិថិជនមិនមែនធនាគារ......៣
រូបភាពទី ៥: ឥណទាន និង ប្រាក់បញ្ញើធៀបនឹងផលិតផលក្នុងស្រុកដុល......៤
រូបភាពទី ៦: កំណើនឥណទាន និង ប្រាក់បញ្ញើ......៤
រូបភាពទី ៧: ឥណទានតាមវិស័យ......៥
រូបភាពទី ៨: ឥណទានមិនដំណើរការ......៥
រូបភាពទី ៩: អនុបាតប្រាក់ចំណេញរបស់ធនាគារ......៦
រូបភាពទី ១០: អនុបាតប្រុងប្រយ័ត្ន......៦
រូបភាពទី ១១: ឥណទាន និងប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ......៧
រូបភាពទី ១២: អនុបាតសាធនភាព......៨
រូបភាពទី ១៣: អនុបាតសាច់ប្រាក់ងាយស្រួល......៨
រូបភាពទី ១៤: ឥណទានមិនដំណើរការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ......៨
រូបភាពទី ១៥: អនុបាតហានិភ័យធំ និងសម្ព័ន្ធញាតិរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ......៩

# តារាងអក្សរកាត់

| | |
|---|---|
| ADB | Asian Development Bank |
| AML/CFT | Anti-Money Laundering/Combating the Financing of Terrorism |
| APG | Asia Pacific Group on Money Laundering |
| ATM | Automatic Teller Machines |
| AUSTRAC | Australian Transaction Reports and Analysis Center |
| CMA | Cambodian Microfinance Association |
| FATF | Financial Action Task Force |
| FDI | Foreign Direct Investment |
| FIU | Financial Intelligence Unit |
| GDP | Gross Domestic Product |
| IFC | International Financial Corporation |
| IMF | International Monetary Fund |
| KHR | Khmer Riel |
| ME | Mutual Evaluation |
| MFIs | Microfinance Institutions |
| NBC | National Bank of Cambodia |
| NGO | Non-Governmental Organization |
| NPO | Non-Profit Organization |
| NPL | Non-Performing Loan |
| PC | Partially Compliant |
| ROA | Return on Assets |
| ROE | Return on Equity |
| UNDP | United Nations Development Program |
| UNODC | United Nations Office of Drugs and Crime |
| USD | US Dollar |

## ១. ការប្រព្រឹត្តិទៅនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

បរិយាកាសនយោបាយនិងម៉ាក្រូសេដ្ឋកិច្ចមានស្ថិរភាពនាបណ្តាឆ្នាំកន្លងមកនេះ បានបង្ហាញឱ្យឃើញតាមរយៈកំណើនសកម្មភាពសេដ្ឋកិច្ច ការចំណាយរដ្ឋាភិបាលនិងវិស័យឯកជន អត្រាប្តូរប្រាក់មានស្ថិរភាព និងគោលនយោបាយសារពើពន្ធគាំទ្រ បាននាំឱ្យមានកំណើនកាលានុវត្តភាពវិនិយោគនិងតម្រូវការឥណទានជាបន្តបន្ទាប់ ។ បើធៀបឆ្នាំ ២០០៦ ការប្រព្រឹត្តិទៅនៃប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុមានលក្ខណៈល្អប្រសើរឡើង ដោយរក្សាបាននូវស្ថិរភាព និងសុវត្ថិភាពតាមរយៈកំណើនទ្រព្យសកម្ម កំណើនប្រាក់បញ្ញើ និងឥណទានមិនដំណើរការមានកំរិតទាប ។ ទ្រព្យសកម្មនិងប្រាក់បញ្ញើសរុបដែលកាន់កាប់ដោយធនាគារ មានការកើនឡើងគួរឱ្យកត់សំគាល់ដោយធាតុនីមួយៗមានកំណើនប្រមាណ ៧៤% ។

កំណើននៃចំនួនធនាគារ និងចំនួននៃសាខានៅតាមខេត្តក្រុង និងទំនើបកម្មផលិតផលនិងសេវាកម្មធនាគារ ដូចជាម៉ាស៊ីនបើកប្រាក់ដោយស្វ័យប្រវត្តិ (ATMs[1]), Internet Banking, Credit Cards, Debit Cards, ការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក (Wire Transfer) និងសេវាកម្មទំនើបផ្សេងៗទៀត បានធ្វើឱ្យសាធារណជនមានភាពងាយស្រួល និងទទួលស្គាល់ពីសារប្រយោជន៍នៃការប្រើប្រាស់សេវាធនាគារ ។ ការទាក់ទាញជំនឿទុកចិត្តពីសាធារណជននេះ បានបង្ហាញឱ្យឃើញតាមរយៈការកើនឡើងនៃចំនួនអតិថិជនចំនួន ៥៩,៦% ពី ២៨៥.៦៣៩ នាក់ ក្នុងឆ្នាំ ២០០៦ ដល់ ៤៥៦.០២៦ នាក់ ក្នុងឆ្នាំ ២០០៧ ចំណែកឯប្រាក់បញ្ញើបានកើនឡើងចំនួន ៧៤% គឺកើនឡើងពី ៥.៦៨៧ ពាន់លានរៀល (១.៤០១,៧ លានដុល្លារអាមេរិក) ក្នុងឆ្នាំ ២០០៦ ដល់ ៩.៩២២ ពាន់លានរៀល (២.៤៨០ លានដុល្លារអាមេរិក) ក្នុងឆ្នាំ២០០៧ ។ ការកើនឡើង យ៉ាងឆាប់រហ័សនៃប្រាក់បញ្ញើ គឺអាស្រ័យដោយមានជំនឿទុកចិត្តពីប្រជាជនខ្មែររស់នៅបរទេសដែលបានបង្វិលទុនចូលក្នុងស្រុក ។ លើសពីនេះទៅទៀត ការកើនឡើងនេះក៏អាស្រ័យដោយការរីកចំរើននៃវិស័យអចលនទ្រព្យ ។ ប្រាក់ដែលធ្លាប់តែរក្សាទុកនៅតាមផ្ទះត្រូវបានអ្នកវិនិយោគលើការសាងសង់យកមកដាក់ចូលក្នុងប្រព័ន្ធធនាគារតាមរយៈការលក់ដូរផ្ទះសំបែង និងអចលនទ្រព្យ ។

**រូបភាពទី១: ចំនួនអ្នកដាក់ប្រាក់បញ្ញើ និងអ្នកខ្ចីប្រាក់**







[1] *មុនឆ្នាំ ២០០៦ ចំនួន ATM មានចំនួនត្រឹមតែ ៦៩ ប៉ុណ្ណោះ ។ គិតមកដល់ចុងឆ្នាំ២០០៧ ATM សរុបមានចំនួន ១៧៧ គ្រឿង ។*

ការពង្រីកទំហំសកម្មភាពអាជីវកម្មរបស់វិស័យធនាគារ និងហិរញ្ញវត្ថុបានបង្ហាញឱ្យឃើញតាមរយៈកំណើននៃចំនួនបុគ្គលិកសរុបក្នុងវិស័យធនាគារ ។ តាមតារាងទី២ ក្នុងឧបសម្ព័ន្ធទី២ បុគ្គលិកសរុបរបស់វិស័យធនាគារបានកើនឡើងពី ៣.៨៦៦ នាក់ ឆ្នាំ ២០០៥ ដល់ ៤.៦២៤ នាក់ ឆ្នាំ ២០០៦ និងដល់ ៦.៨៦៩ នាក់ ឆ្នាំ ២០០៧ ។

## ១.១. រចនាសម្ព័ន្ធតារាងតុល្យការធនាគារ

ការវិភាគលើរចនាសម្ព័ន្ធតារាងតុល្យការ គឺដើម្បីកំណត់ពីប្រភេទនិងការរីកដុះដាលឡើងនៃសកម្មភាពអាជីវកម្មរបស់ធនាគារ ក៏ដូចជាដើម្បីពិចារណាលើឥទ្ធិពលនៃការប្រែប្រួលទាំងនេះ ចំពោះទំរង់ហានិភ័យនៃប្រព័ន្ធធនាគារ ។ ទ្រព្យសកម្មសរុបរបស់ប្រព័ន្ធធនាគារនៅកម្ពុជានាចុងឆ្នាំ ២០០៧ មានចំនួន ១៣.៤៤៥ ពាន់លានរៀល បើធៀបនឹងឆ្នាំ ២០០៦ មានចំនួន ៧.៧១៦ ពាន់លានរៀល ពោលគឺកើនឡើងយ៉ាងខ្លាំងចំនួន ៧៤% ។ សាច់ប្រាក់ដែលបានមកពីប្រាក់បញ្ញើរបស់អតិថិជនមិនមែនធនាគារជាមូលហេតុចំបងមួយនៃកំណើនទាំងនេះ ។ កំណើនដ៏លឿននេះបានធ្វើឱ្យអនុបាតទ្រព្យសកម្មសរុបធៀបនឹងផលិតផលក្នុងស្រុកដុល (GDP) កើនដល់ ៤១% ពោលគឺខ្ពស់ជាងឆ្នាំមុនចំនួន ១៥% ។

**រូបភាពទី — ២ : ទ្រព្យសកម្មសរុប និងផលិតផលក្នុងស្រុកដុល**




ប្រសិនបើទ្រព្យសកម្មសរុបរបស់ធនាគារត្រូវបានប្រើជាលក្ខខណ្ឌដើម្បីកំណត់ពីទំហំរបស់ធនាគារ នោះមានធនាគារធំៗចំនួនបួន ដែលកាន់កាប់ទ្រព្យសកម្មសរុបចំនួន ៦៤% នៃទ្រព្យសកម្មសុទ្ធសរុបរបស់ប្រព័ន្ធធនាគារនាចុងឆ្នាំ ២០០៧ នេះ ។ បើប្រៀបធៀបទៅឆ្នាំ ២០០៦ ធនាគារធំៗទាំងបួនកាន់កាប់ទ្រព្យសកម្មសរុបចំនួន ៥៥% ។ សូចនាករទាំងនេះបង្ហាញអំពីការប្រមូលផ្តុំ និង វិសមភាគភាព នៃប្រព័ន្ធធនាគារនៅកម្ពុជា ។

## រូបភាពទី ៣: សមាសភាពទ្រព្យសកម្ម និង ទ្រព្យអកម្ម




គិតត្រឹមចុងឆ្នាំ ២០០៧ នេះ ប្រាក់បញ្ញើអតិថិជនមិនមែនធនាគារធៀបនឹងទ្រព្យអកម្មមានការថយចុះបន្តិច ពី ៧៤,៥% មក ៧៤% ធៀបនឹងឆ្នាំ២០០៦ ។ ការថយចុះនេះបណ្តាលមកពីសមាសធាតុនៃមូលធនមានការកើនឡើងតាមរយៈការបង្កើនដើមទុន និងវត្តមានរបស់ធនាគារថ្មីៗ ។

## រូបភាពទី ៤ :
## សមាសភាពប្រាក់បញ្ញើរបស់អតិថិជនមិនមែនធនាគារ




ស្ទើរតែពាក់កណ្តាលនៃប្រាក់បញ្ញើសរុប ជាប្រាក់បញ្ញើសន្សំចំនួន ៤៧% រីឯប្រាក់បញ្ញើមានកាលកំណត់ ប្រាក់បញ្ញើតាមតម្រូវការ និងប្រាក់បញ្ញើផ្សេងៗមានចំនួន ២៨% ២៤% និង ១% រៀងគ្នា ។ លើសពីនេះទៅទៀតបើប្រៀបធៀបទៅឆ្នាំ ២០០៦ ប្រាក់បញ្ញើនេះបានកើនឡើងរហូតដល់ទៅ ៧៤% ក្នុងនោះប្រាក់បញ្ញើសន្សំកើនខ្ពស់ជាងគេគឺ ១០១% បន្ទាប់មកប្រាក់បញ្ញើតាមតម្រូវការ ៦៤% ប្រាក់បញ្ញើមានកាលកំណត់ ៥២% និងប្រាក់បញ្ញើផ្សេងៗ ២៨% ។

### ១.២. ឥណទាន និង ប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារ

គិតមកដល់ឆ្នាំ២០០៧ អតិថិជនដែលបានទទួលឥណទានពីធនាគារមានចំនួន ១៩៧.៣៣៧ នាក់ គឺកើនឡើងចំនួន ១៩,៦% បើធៀបនឹងឆ្នាំ ២០០៦ ដែលមានចំនួន ១៦៤.៩៣១ នាក់ ។ បើពិនិត្យលើភាគរយនៃឥណទានធៀបនឹង GDP បានកើនឡើងដល់ ១៨,៣% ក្នុងឆ្នាំ២០០៧ ខណៈដែលឆ្នាំ២០០៦ មាន ១២,២% និងឆ្នាំ២០០៤ មានត្រឹមតែ ចំនួន ៨,៥% ប៉ុណ្ណោះ ។ ចំណែកឯប្រាក់បញ្ញើធៀបនឹង GDP បានកើនឡើងពី ១៧,៩% ក្នុងឆ្នាំ ២០០៦ ដល់ ២៦,៨% ក្នុងឆ្នាំ ២០០៧ ។

រូបភាពទី ៥: ឥណទាន និង ប្រាក់បញ្ញើធៀបនឹងផលិតផលក្នុងស្រុកដុល




គិតមកដល់ឆ្នាំ ២០០៧ គ្រឹះស្ថានធនាគារ បានផ្តល់ឥណទានសរុបចំនួន ៦.៣៣៦ ពាន់លានរៀល (១.៥៨២ លានដុល្លារអាមេរិក) កើនឡើងប្រមាណ ៧៧% ធៀបនឹងឆ្នាំ ២០០៦ ដែលមានចំនួន ៣.៥៧៩ ពាន់លានរៀល (៨៨២ លានដុល្លារអាមេរិក) ។ ទោះបីជាយ៉ាងណាក៏ដោយការផ្តល់ឥណទាននេះមានតែ ៦៤% នៃប្រាក់បញ្ញើប៉ុណ្ណោះ ។

ឥណទាននេះ បានផ្តល់ទៅលើវិស័យសេដ្ឋកិច្ចសំខាន់ៗ រួមមាន : វិស័យសេវាកម្មបានកើនឡើងចំនួន ៥៧% ការលក់ដុំ និងរាយបានកើនឡើង ៧៥% អចលនទ្រព្យ និងការប្រើប្រាស់សាធារណៈបានកើនឡើង ៦៥% និងវិស័យឧស្សាហកម្មបានកើនឡើង ៥២% ការសាងសង់បានកើនឡើង ១៣៨% ។ ការកើនឡើងនេះ គឺស្របទៅនឹងកំណើនសេដ្ឋកិច្ចដែលកើនប្រមាណ ៩,៦% ក្នុងឆ្នាំ ២០០៧ ។ ឥណទានទៅវិស័យសេវាកម្ម និងលក់ដុំ និងរាយ នៅតែមានកំរិតខ្ពស់ជាងវិស័យដទៃទៀតនៃចំណែកទីផ្សារ ។

រូបភាពទី ៦: កំណើនឥណទាន និង ប្រាក់បញ្ញើ




ការកើនឡើងយ៉ាងខ្លាំងនៃឥណទាននេះមិនធ្លាប់មានពីមុនមកនោះទេ ។ ទន្ទឹមនឹងគ្នានេះដែរឥណទានមិនដំណើរការរបស់វិស័យធនាគារក៏មានកំរិតទាបបំផុតដែលមិនធ្លាប់មានគឺ ៣,៤% ។ ហេតុការណ៍ទាំងពីរខាងលើនេះ បានធ្វើឱ្យធនាគារជាតិនៃកម្ពុជា មានការព្រួយបារម្ភយ៉ាងខ្លាំងលើការធ្វើចំណាត់ថ្នាក់ឥណទានមិនដំណើរការនៅតាមបណ្តាធនាគារ ជាពិសេសលើតម្លាភាពនៃដំណើរការអនុម័តឥណទាន ។ ដោយសារតែមានការលំបាកក្នុងការទទួលបាននូវរបាយការណ៍

**រូបភាពទី ៧: ឥណទានតាមវិស័យ**




ហិរញ្ញវត្ថុពីអ្នកខ្ចី ជាពិសេសរបាយការណ៍ហិរញ្ញវត្ថុ ដែលអាចជឿទុកចិត្តបាន ធនាគារមួយចំនួននៅតែបន្ត ធ្វើចំណាត់ថ្នាក់ សំពៀតឥណទានដោយផ្អែកលើរូបមន្ត ហួសកាលកំណត់សង និងមិនបានគិតពីស្ថានភាព ហិរញ្ញវត្ថុរបស់អ្នកខ្ចីទេ ។ ដូច្នេះហើយ ជាទូទៅការ សំរេចអនុម័តឥណទាន គឺធ្វើឡើងដោយផ្តោតទៅលើ បទពិសោធន៍ ដែលបានជួបប្រទះពីមុនជាមួយនឹងអតិថិជននីមួយៗតាមជាក់ស្តែង ។ ចំណុចដែលគួរឱ្យកត់សម្គាល់មួយទៀត គឺអនុបាតនៃសំវិធានធនទូទៅធៀប នឹងឥណទានសរុបមានការធ្លាក់ចុះពី ០,៨% នៅឆ្នាំ២០០៦ មកនៅត្រឹម ០,៧% ក្នុងឆ្នាំ២០០៧ ។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាកំពុងរៀបចំសេចក្តីព្រាងប្រកាសពាក់ព័ន្ធនឹងការកំណត់អត្រាសំវិធានធនទូទៅ ឱ្យធនាគារអនុវត្ត ឆ្លើយតបទៅនឹងការវិវត្តន៍និងការអនុវត្តន៍ជាក់ស្តែង ។

**រូបភាពទី ៨: ឥណទានមិនដំណើរការ**




## ១.៣. អនុបាតប្រុងប្រយ័ត្ន

ពិនិត្យជារួម អនុបាតលទ្ធភាពរកប្រាក់ចំណេញរបស់ប្រព័ន្ធធនាគារទាំងមូល បានបង្ហាញឱ្យឃើញកំណើននៃប្រាក់ចំណេញជាបន្តបន្ទាប់ រហូតមកដល់បច្ចុប្បន្ន ។ អនុបាតសំខាន់សំរាប់វាស់វែងលទ្ធភាពរកចំណេញរបស់ធនាគារមានដូចជាប្រាក់ចំណេញធៀបនឹងទ្រព្យសកម្មសរុប (ROA) និងប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិក (ROE) ។ រយៈពេលពីរឆ្នាំកន្លងមកនេះ យើងបានពិនិត្យឃើញថា អនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិកបានកើនឡើងយ៉ាងខ្លាំងពី ៧,៩% ក្នុងឆ្នាំ ២០០៥ ដល់ ១៦,៣% ក្នុងឆ្នាំ ២០០៧ ។

លទ្ធផលនៃប្រាក់ចំណេញនេះគឺអាស្រ័យដោយមានចំណូលមិនមែនការប្រាក់បានកើនឡើងចំនួន ៧១% និងចំណូលការប្រាក់បានកើនឡើងចំនួន ៧៩% ។ លើសពីនេះការប្រមូលបានមកវិញនូវបំណុលនៃឥណទានមិនដំណើរការ មានចំនួនគួរឱ្យកត់សំគាល់ គឺស្មើនឹង ៣០% នៃប្រាក់ចំណេញប្រចាំឆ្នាំ ។

**រូបភាពទី ៩: អនុបាតប្រាក់ចំណេញរបស់ធនាគារ**




ភាពរីកចម្រើននៃសេវាហិរញ្ញវត្ថុគឺជាព័ត៌មានដ៏ល្អសម្រាប់អ្នកប្រើប្រាស់ និងវិនិយោគិន ប៉ុន្តែសេវាទាំងនោះ គឺត្រូវបានភ្ជាប់ជាមួយហានិភ័យ ដែលគ្រឹះស្ថានទាំងនោះត្រូវការពារយ៉ាងប្រុងប្រយ័ត្នបំផុតដើម្បីរក្សាស្ថិរភាពអតិថិជន និងស្ថាប័នរបស់ខ្លួន ។ ក្នុងន័យនេះ នាយកដ្ឋានត្រួតពិនិត្យជាផ្នែកមួយដ៏សំខាន់ក្នុងការជួយទប់ស្កាត់ស្ថាប័នទាំងនោះមិនឱ្យធ្វើប្រតិបត្តិការណាដែលមានហានិភ័យខ្ពស់ តាមរយៈការត្រួតពិនិត្យនិង តាមដានការអនុវត្តច្បាប់ បទបញ្ញត្តិ និងបទបញ្ជានានា ដែលធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យអនុវត្ត ។

អនុបាតសាធនភាពមានចំនួន ២៣,៥៧% លើសពីការកំណត់ ១៥% ប៉ុន្តែមានកំរិតទាបជាងឆ្នាំមុន ដោយសារកំណើនឥណទានមានកំរិតខ្ពស់ ។ ទន្ទឹមនឹងនេះឥណទានមានហានិភ័យធំបានថយចុះពីចំណុចខ្ពស់បំផុត ៩០,៤% ក្នុងឆ្នាំ ២០០៥ មកត្រឹម ៩,១៣% ក្នុងឆ្នាំ២០០៧ អាស្រ័យដោយការកែប្រែវិធីសាស្ត្រនៃការគណនា និងការត្រួតពិនិត្យដ៏តឹងរឹងលើឥណទាន បែបនេះ ។

ការត្រួតពិនិត្យលើការអនុវត្តតាមបទបញ្ញត្តិប្រុងប្រយ័ត្ននានា គឺសំដៅរក្សាស្ថិរភាព សុវត្ថិភាព និង ចីរភាពនៃប្រព័ន្ធធនាគារទាំងមូល ។ បទបញ្ញត្តិប្រុងប្រយ័ត្នសំខាន់ៗទាំងនោះ រួមមាន ៖ ឥណទានមិនដំណើរការ ឥណទានចំពោះសម្ព័ន្ធញាតិ ឥណទានមានហានិភ័យធំ ភាពគ្រប់គ្រាន់នៃដើមទុនជាដើម ។

**រូបភាពទី ១០: អនុបាតប្រុងប្រយ័ត្ន**



## ១.៤. រចនាសម្ព័ន្ធតារាងតុល្យការនិងការអភិវឌ្ឍន៍វិស័យមីក្រូហិរញ្ញវត្ថុ

ក្នុងឆ្នាំ ២០០៧ ធនាគារជាតិនៃកម្ពុជា បានរៀបចំសន្និសីទជាតិ និងសន្និសីទតំបន់ ចំនួន ២ លើក ។ លើកទី១នៅខេត្តកំពង់ចាម និងលើកទី២នៅទីក្រុងភ្នំពេញ ដោយមានកិច្ចសហប្រតិបត្តិការជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ សមាគមមីក្រូហិរញ្ញវត្ថុ និងធនាគារអេអុិនហ្សេត្សូយ៉ាល់ ។ សន្និសីទទាំងនេះ ជាវេទិកាសាធារណៈ ដើម្បីផ្សព្វផ្សាយឱ្យសាធារណជនបានយល់ដឹងកាន់តែច្រើនឡើង អំពីសេវាមីក្រូហិរញ្ញវត្ថុ ជាពិសេសអំពីបែបបទចូលមកកាន់សេវាមីក្រូហិរញ្ញវត្ថុ និង ការប្រើប្រាស់ប្រាក់ដែលបានខ្ចី ។ ម្យ៉ាងទៀត ដើម្បីឱ្យគ្រឹះស្ថានអាចមានលទ្ធភាពរកប្រភពទុនក្នុងស្រុក ក្នុងឆ្នាំ ២០០៧ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណ ទទួលប្រាក់បញ្ញើពីសាធារណជន និងបានរៀបចំឱ្យប្រសើរឡើងនូវប្លង់គណនីសំរាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអនុវត្ត ។

គិតមកដល់ដំណាច់ឆ្នាំ ២០០៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ និងប្រតិបត្តិករឥណទានជនបទដែលបានចុះបញ្ជី បានផ្តល់ឥណទានសរុបចំនួនប្រមាណ ៦៤១ ពាន់លានរៀល គឺមានការកើនឡើងចំនួន ៧១% បើធៀបនឹងឆ្នាំ ២០០៦ ដែលមានឥណទានត្រឹមតែ ៣៧៤ ពាន់លានរៀល ។ អតិថិជនដែលទទួលបានឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានចំនួន ៦២៨.០៨៩ នាក់ កើនឡើង ៣២% ប្រៀបធៀបឆ្នាំ ២០០៦ ដែលមានអតិថិជនចំនួនតែ ៤៧១.០២៦ នាក់ ។ ប្រាក់បញ្ញើសរុបមានចំនួនប្រមាណ ២៤ ពាន់លានរៀល កើនឡើង ១០៣% ប្រៀបធៀបនឹងឆ្នាំ ២០០៦ និងមានអ្នកដាក់ប្រាក់បញ្ញើមានចំនួនប្រមាណ ១៤៧.៩៦៦ នាក់ កើនឡើង ៣០% ប្រៀបធៀបនឹងឆ្នាំ ២០០៦ ។

**រូបភាពទី ១១: ឥណទាន**
**និងប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**




ប្រតិបត្តិការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនមានការរីកចំរើនគួរឱ្យកត់សំគាល់ ដែលបានរួមចំណែកក្នុងការផ្តល់សេវាហិរញ្ញវត្ថុនៅជនបទដើម្បីបង្កើនចំណូលក្នុងគ្រួសារ និងការកាត់បន្ថយភាពក្រីក្រ ។ ការរីកចំរើននេះ គឺមានមួយផ្នែកដែលអាស្រ័យដោយវិនិយោគទុនបន្ថែមពីបរទេស ។

អតិថិជនភាគច្រើនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាប្រជាកសិករប្រកបរបរកសិកម្ម ដែលមានប្រមាណ ៦០% នៃអ្នកខ្ចីសរុប និងក្រៅពីនោះជាអាជីវករតូចតាចនៅតាមជនបទ ។ អតិថិជនក៏បានបង្ហាញឱ្យឃើញផងដែរថា ការប្រើប្រាស់សេវាកម្មឥណទាន និងការប្រមូលប្រាក់សន្សំរបស់គ្រឹះស្ថានបានជួយសំរាលបន្ទុក និងជួយអភិវឌ្ឍជីវភាពរបស់ពួកគាត់បានធូរស្រាលមួយកម្រិត និងធ្វើឱ្យពួកគាត់កាន់តែយល់ច្បាស់ពីផលប្រយោជន៍នៃការចូលរួមទទួលសេវាហិរញ្ញវត្ថុពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។

យោងតាមប្រកាស របស់ធនាគារជាតិនៃកម្ពុជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវរក្សាអនុបាតសាធនភាពយ៉ាងតិចបំផុត ១៥% ។ ការថយចុះនៃអនុបាតសាធនភាពបណ្តាលមកពីការកើនឡើងនៃឥណទាន ។ ទោះជាយ៉ាងណាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅតែត្រូវការទុនបន្ថែមទៀត ដើម្បីពង្រីកប្រតិបត្តិការរបស់ខ្លួន និងបំពេញតំរូវការអតិថិជន ។

**រូបភាពទី ១២: អនុបាតសាធនភាព**




ក្នុងឆ្នាំ ២០០៤ ២០០៥ ២០០៦ និង ២០០៧ អនុបាតសាច់ប្រាក់ងាយស្រួលមានចំនួន ១៣.៨១០% ៣.៦៣០% ៤.០៥០% និង ២.៦១៣% ។ យោងលើតួលេខនេះបង្ហាញថា វិស័យមីក្រូហិរញ្ញវត្ថុមានសាច់ប្រាក់ងាយស្រួលខ្ពស់ដោយសារទ្រព្យសកម្មភាគច្រើន របស់គ្រឹះស្ថានជាទ្រព្យសកម្មរយៈកាលខ្លី ហើយម្យ៉ាងទៀតដោយសារវិស័យមីក្រូហិរញ្ញវត្ថុមានប្រាក់បញ្ញើតិច ។

**រូបភាពទី ១៣: អនុបាតសាច់ប្រាក់ងាយស្រួល**




ឥណទានសរុបដែលបានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានការកើនឡើងយ៉ាងខ្លាំងនៅក្នុងឆ្នាំ ២០០៧ គឺកើនឡើង ៧៣% ខណៈដែលអនុបាតឥណទានមិនដំណើរការថយចុះមក ០,២% ។ អនុបាតបំណុលហួសកាលកំណត់សង គឺជាផលធៀបរវាងបំណុលហួសកាលកំណត់សង ចាប់ពី ៣០ ថ្ងៃ និង ឥណទានសរុប ។

**រូបភាពទី ១៤: និន្នាការនៃឥណទានមិនដំណើរការ**



ឥណទានមានហានិភ័យធំត្រូវបានកំណត់ន័យថា ជាឥណទានដល់អត្ថគាហកតែម្នាក់ដែលមានកំរិតលើសពី ១០% នៃមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានឥណទានហានិភ័យធំៗនៅក្នុងឆ្នាំ ២០០៧ ដែលហានិភ័យធំៗនោះស្មើនឹង ១.៣% នៃមូនិធិផ្ទាល់សុទ្ធ ។

**រូបភាពទី ១៥: អនុបាតហានិភ័យធំ និងសម្ព័ន្ធញាតិ**







អនុបាតឥណទានចំពោះសម្ព័ន្ធញាតិធៀបនឹងឥណទានសរុប និងឥណទានចំពោះសម្ព័ន្ធញាតិធៀបនឹង មូលនិធិផ្ទាល់សុទ្ធមានចំនួនតិចជាង ១.៧% ។

ទោះបីជាយើងទទួលបានលទ្ធផលគួរជាទីមោទនៈដូចបានជម្រាបជូនខាងលើក៏ដោយ ប៉ុន្តែយើងនៅមានបញ្ហាសំខាន់ៗមួយចំនួនទៀតត្រូវដោះស្រាយ និងកែលំអឱ្យបានប្រសើរឡើង ដូចជា :

**ក. ឥណទាននៅមានកំរិតទាប**

ឥណទានបានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចទោះជាឥណទានបានកើនឡើងជាបន្តបន្ទាប់ក៏ដោយ កំណើននេះមិនទាន់គ្រប់គ្រាន់សំរាប់បំពេញសេចក្តីត្រូវការនៃសេដ្ឋកិច្ចនៅជនបទនៅឡើយ ។ ដូច្នេះយើងនឹងជំរុញក៏ដូចជាលើកទឹកចិត្តដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ផ្តល់សេវាឥណទានបន្ថែមទៀត ។ កង្វះខាតនៃប្រភពទុនជាពិសេសប្រភពទុនជារូបិយវត្ថុជាបញ្ហាមួយដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកំពុងតែប្រឈមមុខ ។ ក្រៅពីចំណាយប្រតិបត្តិការខ្ពស់ ហានិភ័យអត្រាប្តូរប្រាក់ក៏ជាឧបសគ្គមួយដែលនាំឱ្យអត្រាការប្រាក់មានកំរិតខ្ពស់ និងកំណើនឥណទានទាប ។ ជាលទ្ធផល ធនាគារជាតិនៃកម្ពុជា សហការជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ UNDP និង ធនាគារ អេ អ៊ិន ហ្សេត រ៉ូយ៉ាល់ បានរៀបចំសន្និសីទមួយស្តីពី *ជំហានថ្មីឆ្ពោះទៅមុខ : បង្កើនលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុកាន់តែប្រសើរឡើង* នាខែវិច្ឆិកា ឆ្នាំ ២០០៧ ដែលមានការចូលរួមពីវិស័យមីក្រូហិរញ្ញវត្ថុ ធនាគារពាណិជ្ជ និង ឯកទេសក្នុងស្រុក អ្នកវិនិយោគអន្តរជាតិ និង ស្ថាប័នរដ្ឋពាក់ព័ន្ធដទៃទៀត ក្នុងគោលបំណងជំរុញឱ្យមានការយល់ដឹង បន្ថែមពីសំណាក់វិស័យធនាគារក្នុងស្រុកនូវវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា និងសក្តានុពលរបស់វិស័យនេះ ។ ជាក់ស្តែង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាទូទៅទទួលបានមូលនិធិតាមរយៈប្រភពទុន ឬប្រាក់កម្ចី ជាប្រាក់ដុល្លារអាមេរិក ហើយផ្តល់ឥណទានជាប្រាក់រៀល ដែលធ្វើឱ្យគ្រឹះស្ថានប្រឈមនឹងបញ្ហាស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណ និងអាចទទួលរងនូវវិបត្តិហានិភ័យប្តូរប្រាក់បើសិន

អត្រាប្តូរប្រាក់មានការប្រែប្រួលខ្លាំង ។ ហេតុនេះ ធនាគារជាតិនៃកម្ពុជាបានផ្តល់អនុសាសន៍ឱ្យគ្រឹះស្ថានត្រូវមានយុទ្ធសាស្ត្រស្វែងរកប្រភពទុនជាប្រាក់រៀល តាមរយៈការទទួលប្រាក់កម្ចីជាប្រាក់រៀល ការទទួលការធានាពីតតិយជន ការធ្វើប្រតិបត្តិការ back to back currency ជាមួយគ្រឹះស្ថានធនាគារជាដើម ។ វេទិកាត្រូវបានរំពឹងទុកថាជាឱកាសមួយសំរាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដើម្បីបង្ហាញខ្លួនចំពោះមុខអ្នកវិនិយោគ ដែលអាចផ្តល់ប្រភពទុនបន្ថែមក្នុងតម្លៃមួយសមស្រប ។

### ខ.ការពង្រឹងប្រព័ន្ធមីក្រូហិរញ្ញវត្ថុ

វិស័យមីក្រូហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ថាមានតួនាទីសំខាន់ក្នុងការផ្តល់ប្រភពហិរញ្ញវត្ថុឱ្យដល់ប្រជាពលរដ្ឋក្រីក្រនៅជនបទ និងសហគ្រាសធនតូច-មធ្យម ។ ប៉ុន្តែវិស័យនេះមានការប្រឈមជាច្រើនក្នុងការផ្តល់សេវាហិរញ្ញវត្ថុជនបទ ដូចជា ប្រភពមូលនិធិ គុណភាពធនធានមនុស្ស ការត្រួតពិនិត្យផ្ទៃក្នុងនិងអភិបាលកិច្ចខ្សោយ និងប្រព័ន្ធគណនេយ្យនៅមានកំរិត ។

### គ.ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន សំរាប់វិស័យមីក្រូហិរញ្ញវត្ថុ

ប្រព័ន្ធចែករំលែកព័តិមានឥណទានមានសារៈសំខាន់ណាស់ក្នុងការផ្តល់ឥណទាន និង ពង្រីកប្រតិបត្តិការឥណទានជនបទ ជាពិសេសក្នុងខណៈដែលមានការប្រកួតប្រជែងខ្លាំង រវាងស្ថាប័នមីក្រូហិរញ្ញវត្ថុក្នុងតំបន់ប្រតិបត្តិការ ។ ដូច្នេះកង្វះខាតនៃប្រព័ន្ធចែករំលែកព័តិមានឥណទានសំរាប់ស្ថាប័នមីក្រូហិរញ្ញវត្ថុ ក៏អាចរាប់បានថាជាហេតុផលមួយដែលនាំឱ្យកំណើនឥណទានមានកំរិតទាប និងការចូលរួមក្នុងវិស័យឥណទានជនបទមានកំណត់ ។ តាមរយៈយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០០៦ - ២០១៥ ប្រព័ន្ធចែករំលែកព័តិមានឥណទានដែលត្រូវបានបង្កើតឡើងសម្រាប់ធនាគារពាណិជ្ជអាចពង្រីកដល់វិស័យមីក្រូហិរញ្ញវត្ថុផងដែរ ។

## ២.ការប្រឈមមុខមួយចំនួនរបស់វិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា

### ២.១.កំណើនយ៉ាងឆាប់រហ័សនៃទីផ្សារអចលនទ្រព្យនៅកម្ពុជា

កំណើនយ៉ាងឆាប់រហ័សនៃទីផ្សារអចលនទ្រព្យនៅកម្ពុជាជាកិច្ចការមួយដែលត្រូវយកចិត្តទុកដាក់ជាទីបំផុតដោយសារតែ ៩៨% នៃឥណទាននៅក្នុងប្រទេសត្រូវបានធានាដោយដីធ្លី និងផ្ទះសម្បែង ។ ការវាយតម្លៃការឱ្យខ្ចី មិនបានឆ្លុះបញ្ចាំងពីតម្លៃពិតប្រាកដនៃអចលនទ្រព្យ នៅពេលដែលតម្លៃដី និងផ្ទះកំពុងតែពុះកញ្ជ្រោល ។ លើសពីនេះទៅទៀត ឥណទានលើវិស័យអចលនទ្រព្យមានការកើនឡើងជាលំដាប់ ។ បទពិសោធន៍បានបង្ហាញឱ្យឃើញថា កំណើនឥណទានខ្លាំងលើវិស័យអចលនទ្រព្យបានបណ្តាលឱ្យមានវិបត្តិហិរញ្ញវត្ថុ ជាក់ស្តែងកាលពី១០ឆ្នាំមុន វិបត្តិនេះធ្លាប់កើតមាននៅប្រទេសជិតខាង ។ ដូច្នេះ បញ្ហានេះទាមទារឱ្យមានការត្រួតពិនិត្យយ៉ាងតឹងរ៉ឹង ពីសំណាក់ធនាគារជាតិនៃកម្ពុជា លើឥណទានចំពោះវិស័យអចលនទ្រព្យដែលចាត់ទុកថាមានហានិភ័យខ្ពស់ដើម្បីជៀសវាងវិបត្តិហិរញ្ញវត្ថុ ។ ធនាគារជាតិនៃកម្ពុជាក៏បានយកចិត្តទុកដាក់ផងដែរ លើការធ្វើចំណាត់ថ្នាក់ឥណទានតាមប្រភេទជំនួញ ដើម្បីជៀសវាងការផ្តោតទៅលើឥណទានចំពោះតែវិស័យណាមួយ ដែលបង្កឱ្យមានអតុល្យភាពនៃហានិភ័យសំពៀតឥណទាន ។

### ២.២.ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

តាមរយៈការដាក់ឱ្យអនុវត្តប្រកាសស្តីពីប្រព័ន្ធចែករំលែកព័ត៌មានឥណទានរបស់គ្រឹះស្ថានធនាគារ និងការបង្កើតក្រុមការងារដើម្បីគ្រប់គ្រងការអនុវត្តប្រព័ន្ធនេះឱ្យមានប្រសិទ្ធភាព បញ្ហាប្រឈមសំខាន់ៗមួយចំនួន ដែលត្រូវពិចារណា និងដោះស្រាយ ដូចជា : ត្រូវសុំការអនុញ្ញាតជាមុនពីអតិថិជន ការកំរិតទឹកប្រាក់ត្រូវបញ្ចូលក្នុងប្រព័ន្ធ ព័ត៌មានវិជ្ជមានពីអតិថិជនមិនត្រូវបានដាក់បញ្ចូល ការចូលរួមក្នុងប្រព័ន្ធនេះគឺឈរលើគោលការណ៍ស្ម័គ្រចិត្តរបស់ធនាគារ ។ ក្រៅពីនេះ នៅមានការលំបាកផ្នែកបច្ចេកវិទ្យា ដូចជាប្រព័ន្ធមានភាពយឺតយ៉ាវ មានធនាគារមួយចំនួនតូចប៉ុណ្ណោះ បានដាក់បញ្ចូលព័ត៌មានក្នុងប្រព័ន្ធ ដោយសារបញ្ហា Internet ធនាគារពីរមានការស្ទាក់ស្ទើរក្នុងការចូលជាសមាជិកនៃប្រព័ន្ធនេះ ។

### ២.៣.អភិបាលកិច្ច

អភិបាលកិច្ចនៅតាមបណ្តាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានកត់សំគាល់ថាមានលក្ខណៈខ្សោយដែល ចាំបាច់ត្រូវតែពង្រឹង (ឧទាហរណ៍ គ្រឹះស្ថានខ្លះមិនទាន់មានក្រមសីលធម៌ ឱ្យខ្ចីទៅសម្ព័ន្ធញាតិ និងក្រុមប្រឹក្សាភិបាលមិនមានប្រសិទ្ធភាព) ។ ការបរាជ័យនៃការគ្រប់គ្រងជាទូទៅជាលទ្ធផលមកពី អភិបាលកិច្ចខ្សោយ ។ ដើម្បីពង្រឹងអភិបាលកិច្ច និងបង្កាហានិភ័យនានារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបន្តដាក់ចេញបទបញ្ញត្តិនានាពាក់ព័ន្ធនឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងសវនករខាងក្រៅសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុអនុវត្តដោយអនុលោមតាមការអនុវត្តនិងស្តង់ដារអន្តរជាតិ ជាពិសេសស្របតាមគោលការណ៍ជាមូលដ្ឋានរបស់ Basel នៃការត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាព ។

### ២.៤.ការត្រួតពិនិត្យផ្អែកលើហានិភ័យ

ការត្រួតពិនិត្យផ្អែកលើហានិភ័យពឹងផ្អែកជាសំខាន់លើដំណើរការនៃការគ្រប់គ្រងហានិភ័យផ្ទៃក្នុង ។ ការត្រួតពិនិត្យផ្អែកលើហានិភ័យជាតម្រូវការចាំបាច់ ឬលក្ខខណ្ឌគន្លឹះសម្រាប់ការអនុវត្ត Basel II ។ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលរងការត្រួតពិនិត្យអាចវិភាគហានិភ័យដោយប្រើយុទ្ធសាស្រ្តសមស្រប ដែលបង្កើតដោយអាជ្ញាធរត្រួតពិនិត្យ ។ ធនាគារជាតិនៃកម្ពុជាបានបន្តដោយផ្តោតជាសំខាន់លើការបង្កើតប្រព័ន្ធត្រួតពិនិត្យហានិភ័យក្នុងវិស័យធនាគារ ដើម្បីឆ្ពោះទៅរកការត្រួតពិនិត្យផ្អែកលើហានិភ័យពេញលេញ ដែលជាមូលដ្ឋានសម្រាប់បង្កាជាមុននូវការគំរាមកំហែងដល់ស្ថិរភាពហិរញ្ញវត្ថុ និងសកម្មភាពកែតម្រូវជាបន្ទាន់។

### ២.៥.ប្រតិបត្តិការធនាគារដោយប្រើអេឡិចត្រូនិក

ប្រតិបត្តិការធនាគារដោយប្រើអេឡិចត្រូនិកជាមធ្យោបាយដែលធុរកិច្ចធនាគារត្រូវបានប្រតិបត្តិ តាមរយៈដំណើរស្វ័យប្រវត្តិ (ដូចជា ATM) និងគ្រឿងអេឡិចត្រូនិកផ្សេងៗ ដូចជា កំព្យូទ័រ អ៊ិនធើណែត ទូរស័ព្ទ និងការទូទាត់តាមប័ណ្ណប្លាស្ទិក ។ ដោយចំនួនធនាគារនិងបណ្តាញសាខាបានកើនឡើងជាបន្តបន្ទាប់ ធុរកិច្ចធនាគារមានការប្រកួតប្រជែងយ៉ាងខ្លាំង ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានសិក្សាស្វែងរកនិង អភិវឌ្ឍផលិតផលហិរញ្ញវត្ថុថ្មីៗ ដើម្បីបំពេញបំណងអតិថិជនរបស់ខ្លួន តាមរយៈការផ្តល់សេវារហ័សទាន់ចិត្ត ងាយស្រួលទទួលយកសេវាហិរញ្ញវត្ថុ និងមានតំលៃទាប ។ ក្នុងការប្រើប្រាស់ប្រតិបត្តិការធនាគារ ដោយប្រើអេឡិចត្រូនិកក្នុងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងការប្រើប្រាស់ព័ត៌មានបច្ចេកវិជ្ជានៅក្នុងវិស័យធនាគារ ការបង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិទាក់ទងនឹង ប្រតិបត្តិការធនាគារដោយប្រើអេឡិចត្រូនិកមានសារៈសំខាន់ណាស់ដើម្បីបង្កាប្រាក់របស់អ្នកផ្ញើប្រាក់ ។ ហានិភ័យពាក់ព័ន្ធនឹងប្រតិបត្តិការធនាគារដោយប្រើអេឡិចត្រូនិករួមមានហានិភ័យធនាគារដែលមានទាំងអស់ ។ ធនាគារជាតិនៃកម្ពុជាកំពុងដំណើរការនៃការពិភាក្សាជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីបង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិស្តីពី e-banking ដើម្បីធានាការប្រើប្រាស់មានសុវត្ថិភាព និងធានាបាននូវប្រាក់របស់អ្នកផ្ញើប្រាក់ ។

### ២.៦.ការពង្រឹងសមត្ថភាពមន្ត្រីនាយកដ្ឋានត្រួតពិនិត្យ

ការបណ្តុះបណ្តាលមន្ត្រីត្រួតពិនិត្យ គឺជាអត្ថិភាពដើម្បីជំរុញឱ្យការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពនិងតាមឱ្យទាន់នូវការវិវត្តនៃវិស័យហិរញ្ញវត្ថុ ។ ការវិវឌ្ឍឆាប់រហ័សនៃសេវាកម្មធនាគារ និងការរីកចម្រើនផ្នែក បច្ចេកវិទ្យា និងសេវាអេឡិចត្រូនិក គឺទាមទារឱ្យមន្ត្រីត្រួតពិនិត្យត្រូវតែស្វែងយល់ឱ្យបានច្បាស់លាស់ ព្រោះសេវាថ្មីៗទាំងនោះបានបង្កើតនូវហានិភ័យថ្មីៗបន្ថែមទៀតដែរ ។ ក្រៅពីការបណ្តុះបណ្តាលក្នុងស្រុក នាយកដ្ឋានក៏ទទួលបានការបណ្តុះបណ្តាលពីបណ្តាស្ថាប័នជាច្រើន ដូចជាមូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី SEACEN និងបណ្តាធនាគារកណ្តាលផ្សេងៗ ។

ក្រៅពីសមិទ្ធិផលខាងលើ យើងនៅមានកិច្ចការត្រូវអនុវត្តជាច្រើនទៀតនៅពេលខាងមុខដូចជាបន្តពង្រឹងតាមដានការអនុវត្តច្បាប់របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ចាត់វិធានការកែលំអចំពោះធនាគារដែលអនុវត្តមិនទាន់បានល្អតាមច្បាប់និងបទបញ្ញត្តិ ពិនិត្យឡើងវិញនិងដាក់ចេញនូវបទប្បញ្ញត្តិថ្មីៗឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បន្តបោះផ្សាយ

របាយការណ៍ត្រួតពិនិត្យជាសាធារណៈ បន្តការរៀបចំសន្និសីទផ្សព្វផ្សាយពីសេវាមីក្រូហិរញ្ញវត្ថុនៅកម្ពុជាដល់ប្រជាពលរដ្ឋ ជំរុញឱ្យមានការបង្កើនសមត្ថភាពមន្ត្រីត្រួតពិនិត្យ ដើម្បីដើរឱ្យទាន់ការវិវត្តបច្ចុប្បន្នដើម្បីរួមចំណែកដល់ការពង្រឹងប្រព័ន្ធធនាគារនៅកម្ពុជាឱ្យមានសុខភាពល្អនិងទទួលបានការជឿទុកចិត្តពីអ្នកវិនិយោគទុនក្នុង និងក្រៅប្រទេស ។

**២.៧.ការធ្វើវិសោធនកម្មនិងចេញបទបញ្ញាសម្រាប់ការត្រួតពិនិត្យ ឆ្នាំ២០០៧**

ក្នុងកំឡុងឆ្នាំនេះ ធនាគារជាតិនៃកម្ពុជាបន្តជំរុញឱ្យប្រសើរឡើង នូវតួនាទីត្រួតពិនិត្យនិងចេញបទបញ្ញាតាមរយៈការកែទម្រង់ផ្សេងៗក្នុងក្របខ័ណ្ឌច្បាប់ និងបទបញ្ញាឱ្យស្របតាមការអនុវត្តនិងស្តង់ដារអន្តរជាតិ និងជាពិសេសឱ្យស្របតាមគោលការណ៍ជាមូលដ្ឋានរបស់ Basel សម្រាប់ការត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាព ។ ការប្រែប្រួលដែលគួរឱ្យកត់សំគាល់ទាំងនេះពាក់ព័ន្ធការចេញ និងការធ្វើវិសោធនកម្មបទបញ្ញាផ្សេងៗ រួមមានៈ

-ប្រកាសស្តីពីការធ្វើវិសោធនកម្មប្រកាសស្តីពីអនុបាតសាធនភាពរបស់ធនាគារ

-ប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

-ប្រកាសស្តីពីអនុបាតសាធនភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

-ប្រកាសស្តីពីការត្រួតពិនិត្យរូបិយប័ណ្ណចំហសុទ្ធរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

-ប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន

-ប្រកាសស្តីពីការប្រើប្រាស់ភាសា ឯកត្តារូបិយប័ណ្ណ អត្រាប្តូរប្រាក់ សម្រាប់ចុះកិច្ចបញ្ជិកាគណនេយ្យ និងរាយការណ៍

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានរៀបចំផងដែរនូវសេចក្តីព្រាងបទបញ្ញាពាក់ព័ន្ធនឹង :

-ប្រកាសស្តីពីការចាត់ថ្នាក់ឥណទាន និងសំវិធានធន

-ប្រកាសស្តីពីការប្រើប្រាស់ប្រភពទុនក្នុងស្រុក

-ប្រកាសស្តីពីការផាកពិន័យធនាគារណាដែលរំលោភច្បាប់និងបទបញ្ញា

-ប្រកាសស្តីពីការត្រួតពិនិត្យផ្ទៃក្នុង

-ប្រកាសស្តីពីសវនករខាងក្រៅ

និង សារាចរណែនាំផ្សេងៗ ។

## ៣. ស្ថានភាពការប្រឆាំងការសំអាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម

### ៣.១-ទិដ្ឋភាពទូទៅ

ក្នុងនាមជាប្រទេសសមាជិកនៃប្រទេសក្រុមអាស៊ីប៉ាស៊ីហ្វិកស្តីពីការសំអាតប្រាក់ (APG) ប្រទេសកម្ពុជាត្រូវបំពេញរាល់តម្រូវការទាំងឡាយដែលពាក់ព័ន្ធនឹងការប្រឆាំងការសំអាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម ដោយក្នុងនោះត្រូវគោរពតាមអនុសាសន៍ ៤០ ស្តីពីការសំអាតប្រាក់ និងអនុសាសន៍ពិសេស ៩ ស្តីពីហិរញ្ញប្បទានភេរវកម្មរបស់ក្រុមការងារហិរញ្ញវត្ថុ (FATF) និងនីតិវិធីនៃការវាយតម្លៃប្រកបដោយប្រសិទ្ធភាព ទៅលើហានិភ័យដែលកើតឡើងពីការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

### ៣.២-ច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

ច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រូវបានប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលច្បាប់នេះកំណត់ពីកាតព្វកិច្ចប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម របស់បុគ្គលរាយការណ៍នានា និងបានតម្រូវឱ្យបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ដើម្បីអនុវត្តច្បាប់នេះផងដែរ ។

ក្រៅពីនេះ នាយកដ្ឋានត្រួតពិនិត្យសហការជាមួយជំនាញការរបស់ការិយាល័យអង្គការសហប្រជាជាតិស្តីពីគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) និងធនាគារពិភពលោក កំពុងពិនិត្យសេចក្តីព្រាងប្រកាសស្តីពីការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្មសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដើម្បីឱ្យស្របតាម "ខ" ចែងនៅក្នុងច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

### ៣.៣-អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ (FIU)

ប្រទេសកម្ពុជាត្រូវបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ដើម្បីអនុវត្តច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ ក្រោមជំនួយបច្ចេកទេសរបស់ UNODC ផែនការសម្រាប់បង្កើត FIU ត្រូវបានរៀបចំឡើង ហើយបច្ចុប្បន្ននេះ ធនាគារជាតិនៃកម្ពុជាកំពុងរៀបចំបង្កើតក្រុមប្រឹក្សាភិបាលរបស់អង្គភាពនេះ ដែលមានតួនាទីផ្តល់ការណែនាំដល់ FIU ។

### ៣.៤-ការវាយតម្លៃអញ្ញមញ្ញ (Mutual Evaluation)

ប្រទេសកម្ពុជាបានទទួលរងការវាយតម្លៃអញ្ញមញ្ញក្នុងការអនុវត្តតាមអនុសាសន៍ ៤០ ស្តីពីការប្រឆាំងការសំអាតប្រាក់ និងអនុសាសន៍ពិសេស ៩ ស្តីពីហិរញ្ញប្បទានភេរវកម្មរបស់ក្រុមការងារហិរញ្ញវត្ថុ (FATF) ដោយ ធនាគារពិភពលោក និងក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសំអាតប្រាក់ (APG) ចាប់ពីថ្ងៃទី២៦ ខែកុម្ភៈ ដល់ ថ្ងៃទី ១៤ ខែមិនា ឆ្នាំ២០០៧ ។ លទ្ធផលនៃការវាយតម្លៃត្រូវបានដាក់ជូនមហាសន្និបាតប្រចាំឆ្នាំលើកទី១០ របស់ APG នាខែកក្កដា ឆ្នាំ២០០៧ នៅទីក្រុង

Perth នៃប្រទេសអូស្ត្រាលី ដើម្បីអនុម័តនិងផ្សព្វផ្សាយជាផ្លូវការ ។ ជាលទ្ធផល ប្រទេសកម្ពុជាបានទទួលការវាយតម្លៃថាអនុវត្តបានតាមផ្នែក (PC) ចំនួន ១៣ ក្នុងចំណោមអនុសាសន៍ ៤០ បូក ៩ របស់ក្រុមការងារហិរញ្ញវត្ថុ ។

### ៣.៥_ជំនួយបច្ចេកទេស:

កំឡុងពេល១២ខែកន្លងទៅនេះធនាគារជាតិនៃកម្ពុជាបានទទួលជំនួយបច្ចេកទេសសំខាន់ៗពី UNODC និងធនាគារពិភពលោកតាមរយៈការបណ្តុះបណ្តាល ការរៀបចំឯកសារស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការប្រឹក្សាផ្សេងៗពីបញ្ហាការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មទាំងក្នុងស្រុក និងក្រៅស្រុក ។

នៅក្នុងឆ្នាំ ២០០៧ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយមជ្ឈមណ្ឌលវិភាគ និងរាយការណ៍ប្រតិបត្តិការនៃប្រទេសអូស្ត្រាលី (AUSTRAC) បានរួមគ្នារៀបចំធ្វើសិក្ខាសាលាជាច្រើនរួមមាន កាតព្វកិច្ចប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មសម្រាប់ផ្នែកកាស៊ីណូ អចលនទ្រព្យ អង្គការមិនស្វែងរកប្រាក់ចំណេញ និងសិក្ខាសាលាមួយស្តីពីប្រតិបត្តិការសង្ស័យសម្រាប់ប្រព័ន្ធធនាគារ ។ បន្ថែមលើនេះទៀត ដោយមានកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលនៃប្រទេសបារាំង សិក្ខាសាលាមួយស្តីពីការប្រឆាំងការសំអាតប្រាក់ ត្រូវបានរៀបចំឡើងសម្រាប់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា និងធនាគារពាណិជ្ជ និងធនាគារឯកទេសទាំងអស់ ។

### ៣.៦_ទិសដៅអាទិភាព:

ការបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ និងការចេញប្រកាសថ្មីស្តីពីការប្រឆាំងការសំអាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្មសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ជាអាទិភាពទីមួយ ។ បន្ទាប់មកគឺការបង្កើតយុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលយុទ្ធសាស្ត្រនេះពាក់ព័ន្ធដល់គ្រប់ភ្នាក់ងារពាក់ព័ន្ធ ព្រមទាំងជំនួយបច្ចេកទេសសម្រាប់លើកកម្ពស់ការយល់ដឹងអំពីការប្រឆាំងការសំអាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្មពីបណ្តាម្ចាស់ជំនួយផ្សេងៗ ក៏ជាតម្រូវការផងដែរ ។

# ឧបសម្ព័ន្ធទី ១

## រចនាសម្ព័ន្ធរបស់នាយកដ្ឋានត្រួតពិនិត្យ



# ឧបសម្ព័ន្ធទី ២

# ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅកម្ពុជា

# ឆ្នាំ ២០០៧

(សូមមើលឧបសម្ព័ន្ធទី ២ នៅផ្នែកភាសាអង់គ្លេស)

## ឧបសម្ព័ន្ធទី ៣: អត្រាការប្រាក់លើការឱ្យខ្ចីចងការ (ប្រាក់រៀលនិងប្រាក់រូបិយប័ណ្ណ)

ប្រចាំខែធ្នូ ឆ្នាំ២០០៧ — អត្រាការប្រាក់ប្រចាំឆ្នាំ

| ល.រ | ឈ្មោះធនាគារ | ឱ្យខ្ចីចងការជាប្រាក់រៀល | | | | | ឱ្យខ្ចីចងការជាប្រាក់ដុល្លារអាមេរិក | | | | | ឱ្យខ្ចីជាប្រាក់រូបិយប័ណ្ណផ្សេងៗ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ថ្ងៃ | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | ថ្ងៃ | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | ថ្ងៃ | ១ខែ | ៣ខែ | ៦ខែ | ១២ខែ |
| 1 | ធនាគារអេស៊ីលីដាភីអិលស៊ី | | | | | 24.00% | | | | | 18.00% | | | | | 24.00% |
| 2 | ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ | | | | | | | 14.00% | 15.00% | 16.00% | 18.00% | | | | | |
| 3 | ធនាគារឯកទេស អានកូ | | | | | | | | | | 18.00% | | | | | |
| 4 | ធនាគារ អេ អិន ហ្សិត រ៉ូយ៉ាល់ កម្ពុជា | | | | | | | | | | 9.14% | | | | | |
| 5 | ធនាគារ ឯ.ក.ឱ.កម្ពុជា | | | 21.60% | | | | | 18.00% | 18.00% | 18.00% | | | | | |
| 6 | ធនាគារកម្ពុជាអាស៊ី ចំកាត់ | | | | | | | | | | 18.00% | | | | | |
| 7 | ធនាគារមេគង្គ កម្ពុជា មហាជន ចំកាត់ | | | | | | | 14.40% | 14.40% | 14.40% | 14.40% | | | | | |
| 8 | ធនាគារកម្ពុជាពាណិជ្ជ ចំកាត់ | | | | | | | 18.00% | 18.00% | 18.00% | 18.00% | | | | | |
| 9 | ធនាគារឯកទេស ខេមបូឌាន ឌិវេឡុបមេន | | | | | | | 15.00% | 15.00% | 15.00% | 15.00% | | | | | |
| 10 | ធនាគារកម្ពុជាសាធារណៈ ចំកាត់ | | | | | | | 18.00% | 18.00% | 18.00% | 18.00% | | 18.00% | 18.00% | 18.00% | 18.00% |
| 11 | ធនាគារខេមខូ លីមីតធីត | | | | | | | | | | 10.00% | | | | | |
| 12 | ធនាគារកាណាឌីយ៉ា ក.អ | | 24.00% | 24.00% | 24.00% | 24.00% | | 18.00% | 18.00% | 18.00% | 18.00% | | | | | |
| 13 | ធនាគារពាណិជ្ជទីមួយ សាខាភ្នំពេញ | | | | | | | 13.00% | 13.00% | 13.00% | 13.00% | | | | | |
| 14 | ធនាគារ ឯកទេសវិនិយោគទីមួយ | | | | | | | | 18.00% | 18.00% | 18.00% | | | | | |
| 15 | ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | | 18.00% | 18.00% | 18.00% | 18.00% | | 18.00% | 18.00% | 18.00% | 18.00% | | | | | |
| 16 | ធនាគារក្រុងថៃ ចំកាត់ (មហាជន) | | | | | | | | | | 13.00% | | | | | 10.00% |
| 17 | ធនាគារមេយប៊ែង សាខាភ្នំពេញ | | | | | | | | | | 15.00% | | | | | |
| 18 | ប៉េងហេងអេសអឹមអ៊ី ធនាគារ ចំកាត់ | | | | | | | 24.00% | 24.00% | 24.00% | 24.00% | | | | | |
| 19 | ធនាគារអភិវឌ្ឍន៍ជនបទ | | | | | 15.00% | | | | | 12.00% | | | | | |
| 20 | សាជីវកម្មធនាគារសឹង្ហបូរី ចំកាត់ | | | | | | | | 20.40% | 20.40% | 20.40% | | | | | |
| 21 | ធនាគារសហពាណិជ្ជ ក.អ | | | | | | | | 13.00% | 13.00% | 13.00% | | | | | |
| 22 | ធនាគារវឌ្ឍនៈ | | | | | | | 11.00% | 11.00% | 11.00% | 13.06% | | | | | |
| 23 | ធនាគារឯកទេសវិនិយោគរុងរឿង | | | | | | | 12.00% | | | 12.00% | | | | | |
| | **មធ្យមភាគ** | | **19.01%** | **19.19%** | **19.01%** | **22.26%** | | **16.40%** | **16.76%** | **16.77%** | **16.02%** | | **18.00%** | **18.00%** | **18.00%** | **20.84%** |

## ឧបសម្ព័ន្ធទី ៣ៈ អត្រាការប្រាក់លើប្រាក់បញ្ញើ (ប្រាក់រៀលនិងប្រាក់រូបិយប័ណ្ណ)

ប្រចាំខែធ្នូ ឆ្នាំ២០០៧ — អត្រាការប្រាក់ប្រចាំឆ្នាំ

| ល.រ | ឈ្មោះធនាគារ | ប្រាក់បញ្ញើជាប្រាក់រៀល | | | | | ប្រាក់បញ្ញើជាប្រាក់ដុល្លារអាមេរិក | | | | | ជាប្រាក់រូបិយប័ណ្ណផ្សេងៗ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សំចៃ | មានកាលកំណត់ | | | | សំចៃ | មានកាលកំណត់ | | | | សំចៃ | មានកាលកំណត់ | | | |
| | | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ |
| 1 | ធនាគារអេស៊ីលីដាភីអិលស៊ី | 4.00% | 5.00% | 6.00% | 7.00% | 8.00% | 2.00% | 3.00% | 4.00% | 5.00% | 6.00% | 4.00% | 5.00% | 6.00% | 7.00% | 8.00% |
| 2 | ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ | | 8.20% | 8.25% | | | 1.00% | 2.50% | 3.00% | 4.00% | 5.50% | | | | | |
| 3 | ធនាគារឯកទេស អានកូ | | | | | | | | | | | | | | | |
| 4 | ធនាគារ អេ អិន ហ្សិត រ៉ូយ៉ាល់ កម្ពុជា | 0.50% | 4.55% | 5.60% | 6.55% | 7.70% | 0.50% | 3.75% | 4.00% | 3.90% | 3.65% | | 4.95% | 5.06% | 3.16% | 5.41% |
| 5 | ធនាគារ ឯ.ក.ឧ.កម្ពុជា | 4.00% | | 6.00% | 7.00% | 12.00% | 2.00% | | 3.00% | 3.50% | 4.00% | | | | | |
| 6 | ធនាគារកម្ពុជាអាស៊ី ចំកាត់ | | | | | | 2.50% | 3.00% | 4.00% | 5.00% | 6.00% | | | | | |
| 7 | ធនាគារមេគង្គ កម្ពុជា មហាជន ចំកាត់ | 3.50% | | | | | 2.00% | 2.25% | 2.75% | 3.25% | 3.50% | 2.00% | | | | |
| 8 | ធនាគារកម្ពុជាពាណិជ្ជ ចំកាត់ | 1.25% | | 1.50% | | | 0.50% | | 3.00% | 3.25% | 3.25% | 0.50% | | 1.00% | | |
| 9 | ធនាគារឯកទេស ខេមបូឌាន ឌិវេឡុបមេន | | | | | | | | | | | | | | | |
| 10 | ធនាគារកម្ពុជាសាធារណៈ ចំកាត់ | 1.00% | | | | | 1.00% | 3.50% | 4.00% | 5.00% | 5.00% | | | | | |
| 11 | ធនាគារខេមខូ លីមីតធីត | | | | | | 1.50% | 3.00% | 3.75% | 4.00% | 5.00% | | | | | |
| 12 | ធនាគារកាណាឌីយ៉ា ក.អ | 2.00% | | 4.00% | 5.00% | 6.00% | 0.75% | 3.00% | 4.00% | 4.50% | 6.00% | | | | | |
| 13 | ធនាគារពាណិជ្ជទីមួយ សាខាភ្នំពេញ | | | | | | 0.40% | 1.25% | 1.35% | 1.45% | 1.55% | | | | | |
| 14 | ធនាគារ ឯកទេសវិនិយោគទីមួយ | | | | | | | | | | | | | | | |
| 15 | ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | 1.50% | | 4.50% | 5.50% | 6.50% | 0.75% | 1.00% | 3.00% | 4.00% | 5.00% | | | | | |
| 16 | ធនាគារក្រុងថៃ ចំកាត់ (មហាជន) | | | | | | 1.00% | | 1.50% | 2.00% | 2.00% | | | 1.00% | 1.00% | 1.00% |
| 17 | ធនាគារមេយប៉ែង សាខាភ្នំពេញ | | | | | | 0.75% | 1.75% | 2.00% | 2.50% | 3.25% | | | | | |
| 18 | ប៉េងហេងអែសអឹមអ៊ី ធនាគារ ចំកាត់ | | | | | | | | | | | | | | | |
| 19 | ធនាគារអភិវឌ្ឍន៏ជនបទ | 1.50% | 3.50% | 4.00% | 5.00% | 6.00% | 1.00% | 3.00% | 3.50% | 4.00% | 5.00% | | | | | |
| 20 | សាជីវកម្មធនាគារសឹង្ហបូរី ចំកាត់ | | | | | | 0.50% | | 3.50% | 4.00% | 5.00% | | | | | |
| 21 | ធនាគារសហពាណិជ្ជ ក.អ | | | | | | 1.00% | | 4.00% | 5.00% | 6.00% | | | | | |
| 22 | ធនាគារវឌ្ឍនៈ | | | | | | 1.00% | 3.50% | 4.00% | 4.50% | 6.00% | | | | | |
| 23 | ធនាគារឯកទេសវិនិយោគរុងរឿង | | | | | | | | | | | | | | | |
| | **មធ្យមភាគ** | **1.90%** | **4.85%** | **5.07%** | **6.00%** | **7.05%** | **1.02%** | **2.91%** | **3.64%** | **4.23%** | **4.91%** | **3.40%** | **4.97%** | **5.32%** | **4.71%** | **6.35%** |

# ឧបសម្ព័ន្ធទី ៤: ប្រព័ន្ធធនាគារកម្ពុជា

ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៧

## ធនាគារជាតិ នៃកម្ពុជា

### ១៧ ធនាគារពាណិជ្ជ

#### ៣ សាខាធនាគារបរទេស

- -ធនាគារ ពាណិជ្ជកម្មទីមួយ
- -ធនាគារ ក្រុងថៃ (៧)
- -ធនាគារ មេយបែង

#### ១៤ បង្កើតឡើងតាមច្បាប់ក្នុងស្រុក

- - ធនាគារពាណិជ្ជកម្មក្រៅប្រទេស
- - ធនាគារ វឌ្ឍនៈអាស៊ី (១១)
- -ធនាគារ កម្ពុជាអាស៊ី
- -ធនាគារ កាណាឌីយ៉ា (២)
- -ធនាគារ កម្ពុជាពាណិជ្ជ (១)
- -ធនាគារ កម្ពុជាមេគង្គ (៣)
- -ធនាគារ កម្ពុជាសាធារណៈ (៦)
- - សាជីវកម្ម ធនាគារ សិង្ហបូរី (១០)
- -ធនាគារ សហពាណិជ្ជ (៤)
- -ធនាគារ វឌ្ឍនៈ (៨)
- -ធនាគារ អេស៊ីលីដា (៥)
- -ធនាគារ អេអ៊ិនហ្សេតរ៉ូយ៉ាល់ (៩)
- -ធនាគារខេមខូ
- -ធនាគារ ស៊ិនហាន ខ្មែរ

### ៧ ធនាគារឯកទេស

#### ១ ធនាគាររដ្ឋ

- -ធនាគារ អភិវឌ្ឍន៍ជនបទ

#### ៦ ធនាគារឯកជន

- -ធនាគារ ប៉េងហេង S.M.E.
- -ធនាគារឯកទេសកសិកម្ម - ឧស្សាហកម្ម កម្ពុជា (1)
- -ធនាគារឯកទេសវិនិយោគទីមួយ
- -ធនាគារ ឯកទេសអានកូ
- -ធនាគារ ឯកទេសខេមបូឌាន ឌីវីឡុបមេន
- -ធនាគារឯកទេស វិនិយោគរុងរឿង

#### • ២ ការិយាល័យតំណាង

- - ស្តង់ដារឆាទឺរ៉ែត
- - ធនាគារកសិកម្មនិងអភិវឌ្ឍន៍នៃវៀតណាម

### គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

#### • ១៧ មានអាជ្ញាប័ណ្ណ

1- អម្រឹត
2-ហត្ថាកសិករ
3-តុងហ្វាងមីក្រូហិរញ្ញវត្ថុ
4-ធនាគារភូមិកម្ពុជា
5-សិលានិធិ
6-ក្រុមហ៊ុនស្ថាបនាសហគ្រិនកម្ពុជា
7-ក្រុមហ៊ុនអង្គរមីក្រូហិរញ្ញវត្ថុ
8-វីសុនហ្វាន់(ខេមបូឌា)
9-ក្រុមហ៊ុនក្រេឌីត Co.Ltd.
10-ប្រាសាក់ ម៉ាយក្រូហ្វាយនែន
11-សមាគមមូលនិធិសហភាពអភិ.កសិករ
12-ក្រុមហ៊ុនអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទកម្ពុជា
13-ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ
14-ឥណទានពលរដ្ឋរុងរឿង
15- ស៊ីអេជស៊ី លីមីធីត
16- ពិសិដ្ឋអភិវឌ្ឍន៍សេដ្ឋកិច្ច
17. ឥណទានអភិវឌ្ឍន៍ប្រជាជន

#### អង្គការក្រៅរដ្ឋាភិបាល

- • ២៥ ចុះបញ្ជី *
- • មិនចុះបញ្ជីមានប្រហែល៦០ទៀត

### ២១សាខាធនាគារជាតិនៅតាមខេត្ត

| | |
|---|---|
| -ក្រុងភ្នំពេញ | |
| -កំពង់ចាម | |
| -ក្រុងព្រះសីហនុ | |
| -សៀមរាប | |
| -បាត់ដំបង | |
| -ស្វាយរៀង | |
| -កំពត | |
| -កណ្តាល | -ព្រៃវែង |
| -កំពង់ធំ | -តាកែវ |
| -ពោធិសាត់ | -កំពង់ឆ្នាំង |
| -កំពង់ស្ពឺ | -ព្រះវិហារ |
| -កោះកុង | -ក្រចេះ |
| -រតនៈគីរី | -ស្ទឹងត្រែង |
| -មណ្ឌលគីរី | -បន្ទាយមានជ័យ |

### អាជីវកម្មប្តូរប្រាក់

- • ចុះបញ្ជី 3.808
- -ភ្នំពេញ 556
- -ខេត្ត 3.252

• បើកជាផ្លូវការ

*

| | |
|---|---|
| ១-សមាគមអភិវឌ្ឍន៍កសិករនិងទេសចរ | ១៤-អង្គការឥស្លាមអភិវឌ្ឍន៍ជនបទ |
| ២-សមាគមជួយកសិករ | ១៥- អង្គការអភិវឌ្ឍន៍ជនបទខ្មែរ |
| ៣-សមាគមផ្តើមគំនិតពាណិជ្ជកម្ម | ១៦- សមាគមសុខុមាលស្ត្រីខេត្តក្រចេះ |
| ៤-អង្គការអភិវឌ្ឍន៍សព្វការជាតិខ្មែរ | ១៧- អង្គការលូថេរ៉ានបំរើពិភពលោក |
| ៥-សមាគមសំណាងអភិវឌ្ឍន៍ជនបទ | ១៨- គំរោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ |
| ៦-សមាគមអភិវឌ្ឍន៍ពុទ្ធសាសនានិងទ្រទ្រង់បរិស្ថាន | ១៩- សមាគមអភិវឌ្ឍន៍តំបន់ពាយ័ព្យ |
| ៧-សហព័ន្ធសហគមសន្សំប្រាក់កម្ពុជា | ២០- សមាគមអភិវឌ្ឍន៍ស្រុកស្រែ |
| ៨-ឥណទានលុបបំបាត់ភាពក្រីក្រ | ២១- អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ |
| ៩-អង្គការសង្គហអភិវឌ្ឍន៍កម្ពុជា | ២២- អង្គការអភិវឌ្ឍន៍គ្រួសារជនបទ |
| ១០-អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទនៅកម្ពុជា | ២៣- អង្គការអភិវឌ្ឍន៍សង្គមជនបទ |
| ១១-អង្គការអភិវឌ្ឍន៍ស្ត្រីកម្ពុជា | ២៤- សមាគមអភិវឌ្ឍន៍សណ្តែកសៀងតាអុង |
| ១២-ស៊ីអាយស៊ីអេម កម្ពុជា | ២៥- កម្មវិធីអភិវឌ្ឍន៍ស្ត្រីក្នុងសហគមនៃខ័ណ្ឌមានជ័យ |
| ១៣-សមាគមជាតិទ្រទ្រង់កសិផល | ២៦- អង្គការបណ្តាញសេដ្ឋកិច្ចកម្ពុជា |

| ធនាគារ សាខា | ល.រ | ធនាគារបានបិទ ២៣ | ថ្ងៃ-ខែ-ឆ្នាំដកហូត |
|---|---|---|---|
| (១) បាត់ដំបង, សៀមរាប, ក្រុងព្រះសីហនុ | ៣ | ធនាគារតណទានកម្ពុជាត្រូវបានដកហូតអាជ្ញាប័ណ្ណ | ០៦-ឧសភា-៩៥ |
| (២) ក្រុងព្រះសីហនុ, អូឡាំពិក, បាត់ដំបង, កំពង់ចាម, ក្រុងប៉ៃលិន, ហ្សាដឺហ្គោល, សៀមរាប, ប៉ោយប៉ែត, កំពត, ផ្សារសូរិយា, បន្ទាយមានជ័យ,ពោធិ៍ចិនតុង, តាខ្មៅ, កំពង់ឆ្នាំង, អ្នកលឿង | ១៥ | ធនាគារអភិវឌ្ឍន៍កម្ពុជា (ជំរះបញ្ជីដោយស្ម័គ្រចិត្ត) | ២៤-មិថុនា-៩៦ |
| (៣) រេហ្សិនស៊ីស៏គ្លែ, សៀមរាប, ក្រុងព្រះសីហនុ, ដូនពេញ, ផ្សារកណ្តាល | ៥ | ធនាគារកម្ពុជា រ៉ូយ៉ាល់ (ជំរះបញ្ជីដោយស្ម័គ្រចិត្ត) | ១៩៩៦ |
| (៤) ក្រុងព្រះសីហនុ, សៀមរាប, បាត់ដំបង | ៣ | ធនាគារ ក្រុង បិទ | ០៤-មេសា-៩៨ |
| (៥) ធនាគាររអេស៊ីលីដា : សាខាខេត្ត-ក្រុង | ៣០ | ធនាគារនគរប្លួងថៃសាខាភ្នំពេញ (បញ្ឈប់សកម្មភាព) | ០១-វិច្ឆិកា-៩៨ |
| (៦) សៀមរាប, ក្រុងព្រះសីហនុ, បាត់ដំបង, អូឡាំពិក, កំពង់ចាម, តាខ្មៅ, ច្បារអំពៅ, សេវ៉ាមុនីវង្ស, ទឹកថ្លា, ប៉ោយប៉ែត | ១០ | ធនាគារលីពប៉ូសាខាភ្នំពេញ (បញ្ឈប់សកម្មភាព) | ២៥-មិថុនា-៩៩ |
| (៧) សៀមរាប (សាខារង) | ១ | ធនាគារសាជីវកម្មចាន់សាវ៉ាន់វង្ស (ជំរះបញ្ជីដោយស្ម័គ្រចិត្ត) | ៣១-កក្កដា-០០ |
| (៨) សៀមរាប | ១ | ធនាគារកម្ពុជាអន្តរជាតិ (ជំរះបញ្ជីដោយស្ម័គ្រចិត្ត) | ៣១-កក្កដា-០០ |
| (៩) វិមានឯករាជ្យ,មាត់ទន្លេ,ផ្សារអូឡាំពិក,ក្រមួនសរ, សៀមរាប, ក្រុងព្រះសីហនុ, បាត់ដំបង, ទឹកថ្លា, ពេទ្យលោកសង្ឃ, ផ្សារដើមថ្កូវ, ប៉ោយប៉ែត, កំពុងចាម | ១២ | ធនាគារកសិករកម្ពុជា (ជំរះបញ្ជីតាមបញ្ជា) | ៣១-កក្កដា-០០ |
| (១០) នេរុហ៏, សៀមរាប | ២ | ធនាគារ អង្គរ (ជំរះបញ្ជីដោយស្ម័គ្រចិត្ត) | ៣១-កក្កដា-០០ |
| (1) តាខ្មៅ | ១ | ធនាគារ សកលពាណិជ្ជ (ជំរះបញ្ជីដោយស្ម័គ្រចិត្ត) | ០៨-ធ្នូ-០០ |
| (១១) សៀមរាប | ១ | វិសាលធនាគារ អន្តរជាតិ (ជំរះបញ្ជីដោយស្ម័គ្រចិត្ត) | ០៨-ធ្នូ-០០ |
| **សរុប** | **៨៤** | ធនាគារ សន្តិភាពពាណិជ្ជ (ជំរះបញ្ជីដោយស្ម័គ្រចិត្ត) | ០៨-ធ្នូ-០០ |
| | | ធនាគារបូរីភ្នំពេញ (ជំរះបញ្ជីដោយស្ម័គ្រចិត្ត) | ០៨-ធ្នូ-០០ |
| | | ធនាគារ បាងកកសាខាភ្នំពេញ (ជំរះបញ្ជីដោយស្ម័គ្រចិត្ត) | ០៨-ធ្នូ-០០ |
| | | ធនាគាររីជណែស្សិរណ (ជំរះបញ្ជីតាមបញ្ជា) | ០៨-ធ្នូ-០០ |
| | | ធនាគារពាណិជ្ជកម្ម-កសិកម្មនៃកម្ពុជា (ជំរះបញ្ជីតាមបញ្ជា) | ០៨-ធ្នូ-០០ |
| | | ធនាគារ កសិករថៃមហាជនចំកាត់សាខាភ្នំពេញ ( ជំរះបញ្ជីដោយស្ម័គ្រចិត្ត) | ៣០-មីនា-០១ |
| | | ធនាគារ ក្រៅប្រទេសទីមួយ (ជំរះបញ្ជីតាមបញ្ជា) | ១៩-មីនា-០២ |
| | | ធនាគារសឹង្ហបូរីពាណិជ្ជ (ជំរះបញ្ជីដោយស្ម័គ្រចិត្ត) | ១៩-មីនា-០២ |
| | | ធនាគារ អ័មភីរ៉ូរអន្តរជាតិ (ជំរះបញ្ជីដោយស្ម័គ្រចិត្ត) | ០៤-មេសា-០២ |
| | | ធនាគារ ស្តង់ដាឆាតឺរ៉ែត សុំប្តូរទៅជាការិយាល័យតំណាង | ០១-ឧសភា-០២ |
| | | ក្រេឌីតអាហ្គ្រីកូលអាំងដូស៊ុយអេស៏ ( ជំរះបញ្ជីដោយស្ម័គ្រចិត្ត) | ១៨-កញ្ញា-០២ |

# ឧបសម្ព័ន្ធទី ៥

# គោលការណ៍ស្នូលបាសែល

# សំរាប់ការត្រួតពិនិត្យធនាគារដោយប្រសិទ្ធភាព

## បុព្វកថានៃការពិនិត្យកែលំអ :

១. ឯកសារនេះជាឯកសារកែសំរួលទៅលើគោលការណ៍ស្នូល សំរាប់ការត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាព ដែលគណៈកម្មាធិការត្រួតពិនិត្យប្រព័ន្ធធនាគារបាសែល (គណៈកម្មាធិការ)[១] បានបោះផ្សាយ លើកដំបូងនៅខែ កញ្ញា ឆ្នាំ ១៩៩៧ ។ ស្របជាមួយនឹង*វិធីសាស្ត្រនៃគោលការណ៍ស្នូល*[២] ដែលត្រូវបានប្រទេសនានាប្រើជាមូលដ្ឋានមួយសំរាប់វាយតម្លៃនូវគុណភាពនៃប្រព័ន្ធត្រួតពិនិត្យរបស់ខ្លួន និងសំរាប់កំណត់នូវការងារអនាគត ដែលនឹងត្រូវបំពេញដើម្បីសំរេចបាននូវកំរិតមូលដ្ឋាននៃការត្រួតពិនិត្យដែលអាចទទួលយកបាន ។ បទពិសោធន៏បានបង្ហាញឱ្យដឹងថា ការវាយតំលៃដោយខ្លួនឯងទៅលើការគោរពតាមគោលការណ៍ស្នូលរបស់ប្រទេសនានា ពិតជាអាចជួយអាជ្ញាធរត្រួតពិនិត្យជាពិសេសក្នុងការកំណត់នូវគុណវិបត្តិលើផ្នែកច្បាប់ និងផ្នែកត្រួតពិនិត្យ និងក្នុងការកំណត់អស្ថិរភាព និងដោះស្រាយគុណវិបត្តិទាំងនោះ ។ ការកែសំរួលលើគោលការណ៍ស្នូលបាសែល បានផ្តល់នូវមូលហេតុបន្ថែមសំរាប់ឱ្យប្រទេសនានាធ្វើការវាយតំលៃដោយខ្លួនឯង ។ គោលការណ៍ស្នូលក៏ត្រូវបានប្រើដោយមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងធនាគារពិភពលោកនៅក្នុងកម្មវិធីវាយតំលៃវិស័យហិរញ្ញវត្ថុដើម្បីវាយតំលៃប្រព័ន្ធត្រួតពិនិត្យធនាគារ ក៏ដូចជាការអនុវត្តរបស់បណ្តាប្រទេសនានាផងដែរ ។ ប៉ុន្តែចាប់តាំងពីឆ្នាំ ១៩៩៧ មក មានការប្រែប្រួលយ៉ាងខ្លាំងបានកើតឡើងក្នុងបទបញ្ញត្តិធនាគារ ហើយមាន បទពិសោធន៏យ៉ាងច្រើនបានទទួលពីការអនុវត្តគោលការណ៏ស្នូលនៅក្នុងប្រទេសនានា ព្រមទាំងមានការលេចឡើងយ៉ាងច្បាស់នៃបញ្ហាដែលទាក់ទងនឹងបទបញ្ញត្តិថ្មី ក៏ដូចជាការយល់ដឹងនិងចន្លោះប្រហោងផ្សេងៗ ដែលកើតមាននៅក្នុងបទបញ្ញត្តិ ។ ទាំងអស់នេះហើយដែលជារឿយៗនាំឱ្យមានការចេញផ្សាយថ្មីៗរបស់គណៈកម្មាធិការនេះ ។ ការវិវឌ្ឍន៏ទាំងនេះតម្រូវជាចាំបាច់ឱ្យមានការធ្វើបច្ចុប្បន្នកម្មនូវគោលការណ៏ស្នូល និងវិធីសាស្ត្រវាយតម្លៃនានាដែលទាក់ទង ។

---

*[១] គណៈកម្មាធិការការត្រួតពិនិត្យធនាគារបាសែល ជាគណៈកម្មាធិការនៃអាជ្ញាធរត្រួតពិនិត្យធនាគារដែលត្រូវបានបង្កើតឡើងដោយទេសាភិបាលធនាគារកណ្តាលនៃបណ្តាប្រទេសនានានៅក្នុង G10 ក្នុងឆ្នាំ ១៩៧៥ ។ គណៈកម្មាធិការនេះរួមមានតំណាងជាន់ខ្ពស់នៃ អាជ្ញាធរត្រួតពិនិត្យ ធនាគារ និងធនាគារកណ្តាលនានាមកពីប្រទេសបេលស៊ិក កាណាដា បារាំង អាល្លឺម៉ង់ អ៊ីតាលី ជប៉ុន លុចស៊ំបួរ ហូឡង់ អេស្ប៉ាញ ស៊ុយអ៊ែត ស្វីស ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ។ ពួកគេជាទូទៅជួបប្រជុំគ្នានៅ Bank for International Settlements នៅទីក្រុងបាសែល ដែលជាទីស្នាក់ការអចិន្ត្រៃរបស់អគ្គលេខាធិការដ្ឋាន ។*

*[២] បន្ថែមពីលើគោលការណ៏ទាំងនោះ គណៈកម្មាធិការបានបង្កើតនូវសេចក្តីណែនាំដែលមានលក្ខណៈពិស្តារជាងមុន ទៅលើការវាយតំលៃការគោរពតាមគោលការណ៏និមួយៗនៅក្នុងឯកសារវិធីសាស្ត្រនៃគោលការណ៏ស្នូលដែលត្រូវបានគេបោះផ្សាយជាដំបូងនៅក្នុងឆ្នាំ ១៩៩៩ និងត្រូវបានគេធ្វើបច្ចុប្បន្នកម្ម ជាផ្នែកមួយនៃការពិនិត្យកែលំអនេះ ។*

២.	ក្នុងការពិនិត្យកែលំអនូវគោលការណ៍ស្នូលនិងវិធីសាស្ត្រនៃគោលការណ៍ទាំងនេះ គណៈកម្មាធិការមានបំណង ធានានូវនិរន្តរភាព និងភាពស្រដៀងគ្នាទៅនឹងក្របខ័ណ្ឌឆ្នាំ១៩៩៧ ។ ក្របខ័ណ្ឌឆ្នាំ១៩៩៧ បានប្រព្រឹត្តទៅយ៉ាងល្អប្រសើរ និងត្រូវបានគេពិនិត្យឃើញថាអាចរ៉ាប់រងបាននឹងការសាកល្បងតាមពេលវេលាបាន ។ ដូចនេះគោលបំណងនៃឯកសារនេះ មិនមែនសរសេរឡើងវិញនូវគោលការណ៍ស្នូលទាំងស្រុងទេ ប៉ុន្តែគឺគ្រាន់តែផ្តោតទៅលើផ្នែកទាំងឡាយណាដែលតម្រូវឱ្យមានការកែសំរួលលើក្របខ័ណ្ឌដែលមានស្រាប់ដើម្បីធានានូវនិរន្តរភាព ។ ការពិនិត្យកែលំអនេះមិនមែនជាការសង្ស័យទៅលើសុពលភាពនៃការងារពីមុនដែលបានអនុវត្តនោះទេ និងជាពិសេសទៅលើការវាយតំលៃ និងរបៀបវារៈនៃការកែទំរង់ដែលផ្អែកទៅលើក្របខ័ណ្ឌឆ្នាំ ១៩៩៧ នោះដែរ ។

៣.	គោលបំណងមួយទៀតនៃការពិនិត្យកែលំអនេះគឺដើម្បីកែលំអនូវភាពស៊ីគ្នារវាងគោលការណ៍ស្នូល និង បទដ្ឋានដែលទាក់ទងដើម្បីសុវត្ថិភាពនិងការធានារ៉ាប់រង ក៏ដូចជាការប្រឆាំងនឹងការសំអាតប្រាក់ និងតម្លាភាពផងដែរ ។ ទោះជាដូច្នេះក៏ដោយ គោលការណ៍ស្នូលតាមផ្នែកត្រូវបានគេរៀបចំឡើងដើម្បីផ្តោតលើផ្នែកដែលមានហានិភ័យសំខាន់ៗ និងចំណុចអាទិភាពនៃការត្រួតពិនិត្យដែលខុសគ្នាពីវិស័យមួយទៅមួយ ហើយភាពខុសគ្នាដែលសមស្របមួយចំនួនត្រូវតែរក្សានៅដដែល ។

៤.	ដើម្បីធ្វើការពិនិត្យកែលំអនេះ គណៈកម្មាធិការបានប្រឹក្សាយ៉ាងជិតស្និទ្ធជាមួយ និងធ្វើការកែលំអនូវការងាររបស់ក្រុមសម្របសម្រួលគោលការណ៍ស្នូល (ជាក្រុមការងារដែលជាទូទៅរួមមានតំណាងជាន់ខ្ពស់ពីបណ្តាប្រទេសជាសមាជិកគណៈកម្មាធិការ អាជ្ញាធរត្រួតពិនិត្យមិនមែនប្រទេស G10 មូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក) ។ គណៈកម្មាធិការក៏បានប្រឹក្សាផងដែរជាមួយស្ថាប័នកំណត់បទដ្ឋានអន្តរជាតិនានា ដូចជា IAIS, IOSCO, FATF និង CPSS ក្នុងអំឡុងពេលរៀបចំសេចក្តីព្រៀង ។ ក្រុមត្រួតពិនិត្យតាម តំបន់ត្រូវបានអញ្ជើញឱ្យផ្តល់អនុសាសន៍[៣] ។មុនពេលបញ្ចប់នូវសេចក្តីព្រាងនេះ គណៈកម្មាធិការបានបើកនូវកិច្ចពិភាក្សាជារួមមួយដែលបើកទូលាយចំពោះអាជ្ញាធរត្រួតពិនិត្យថ្នាក់ជាតិ ធនាគារកណ្តាល សមាគមពាណិជ្ជកម្ម អ្នកសិក្សាស្រាវជ្រាវនានា និងភាគីផ្សេងៗទៀតដែលមានប្រយោជន៍ ។

---

[៣] *គណៈកម្មាធិការត្រួតពិនិត្យធនាគារអារ៉ាប់ សមាគមត្រួតពិនិត្យធនាគារអាមេរិក (ASBA) ក្រុមត្រួតពិនិត្យធនាគារការីប៊ីន ក្រុមការងារត្រួតពិនិត្យធនាគារ EMEAP ក្រុមត្រួតពិនិត្យធនាគារមកពីបណ្តាប្រទេសអ៊ឺរ៉ុបកណ្តាលនិងខាងកើត ក្រុមអ្នកត្រួតពិនិត្យធនាគារដែលនិយាយភាសាបារាំង គណៈកម្មាធិការត្រួតពិនិត្យធនាគារនៃក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ ក្រុមប្រឹក្សាភិបាលសេវាហិរញ្ញវត្ថុជនជាតិអ៊ីស្លាម ក្រុមត្រួតពិនិត្យធនាគារនោយសមុទ្រ ក្រុមត្រួតពិនិត្យតាមតំបន់នៃអាស៊ីកណ្តាលនិង ត្រានកុសកាសៀ អនុគណៈកម្មាធិការត្រួតពិនិត្យធនាគារ SADC វេទិកាអ្នកត្រួតពិនិត្យធនាគារ SEANZA គណៈកម្មាធិការ ត្រួតពិនិត្យធនាគារក្នុងតំបន់អាហ្វ្រិកកណ្តាលនិងខាងលិច និងសមាគមអ្នកត្រួតពិនិត្យហិរញ្ញវត្ថុនៃបណ្តាប្រទេសនៅតំបន់ប៉ាស៊ីហ្វិក ។*

## គោលការណ៍ស្នូល

៥. គោលការណ៍ស្នូលជាក្របខ័ណ្ឌស្តង់ដារអប្បបរមាសំរាប់ការត្រួតពិនិត្យធនាគារដ៏រឹងមាំ និងអាចអនុវត្តបានជាទូទៅ ។ គណៈកម្មាធិការបាសែលបានបង្កើតគោលការណ៍ស្នូលនិងវិធីសាស្រ្ត[៤] ដើម្បីពង្រឹងប្រព័ន្ធហិរញ្ញវត្ថុជាសកល ។ ភាពទន់ខ្សោយនៃប្រព័ន្ធធនាគាររបស់ប្រទេសមួយទោះបីជាប្រទេសកំពុងអភិវឌ្ឍន៍ក្តី ឬ បានអភិវឌ្ឍក្តីអាចគំរាមកំហែងដល់ស្ថិរភាពហិរញ្ញវត្ថុនៅក្នុងប្រទេស និងអន្តរជាតិ ។ គណៈកម្មាធិការបាសែលជឿជាក់ថាការអនុវត្តន៍គោលការណ៍ស្នូលរបស់បណ្តាប្រទេសទាំងឡាយជាជំហានដ៏សំខាន់ឆ្ពោះទៅរកស្ថិរភាព ហិរញ្ញវត្ថុក្នុងស្រុក និងអន្តរជាតិ និងផ្តល់នូវមូលដ្ឋានដ៏ល្អសំរាប់ការអភិវឌ្ឍន៍ប្រព័ន្ធត្រួតពិនិត្យប្រកបដោយ ប្រសិទ្ធភាពនាពេលខាងមុខ ។

៦. គោលការណ៍ស្នូលបាសែលបានកំណត់នូវគោលការណ៍ចំនួន ២៥ ដែលចាំបាច់សំរាប់ឱ្យប្រព័ន្ធត្រួតពិនិត្យមានប្រសិទ្ធភាព ។ គោលការណ៍ទាំងនោះត្រូវបានបែងចែកជា ៧ ក្រុមធំៗៈ គោលបំណង ឯករាជ្យភាព អំណាច តម្លាភាព និងសហប្រតិបត្តិការ (គោលការណ៍ ១) ការផ្តល់អាជ្ញាប័ណ្ណ និងរចនាសម្ព័ន្ធ (គោលការណ៍ ២ ទៅ ៥) បទបញ្ញត្តិប្រុងប្រយ័ត្ន និងលក្ខខណ្ឌតម្រូវនានា (គោលការណ៍ ៦ ទៅ ១៨) វិធីសាស្រ្តនៃការ ត្រួតពិនិត្យធនាគារជាប្រចាំ (គោលការណ៍ ១៩ ទៅ ២១) គណនេយ្យ និងការផ្សព្វផ្សាយជាសាធារណៈ (គោលការណ៍ ២២) អំណាចកែតម្រូវ និងកែលំអរបស់ភ្នាក់ងារត្រួតពិនិត្យ (គោលការណ៍ ២៣) ការត្រួតពិនិត្យប្រមូលផ្តុំ និងទំនាក់ទំនងរវាងភ្នាក់ងារត្រួតពិនិត្យក្នុងស្រុក និងភ្នាក់ងារអន្តរជាតិ (គោលការណ៍ ២៤ ទៅ ២៥) ។ គោលការណ៍ទាំងនោះគឺ[៥] ៈ

## គោលការណ៍ទី ១ ៈ គោលបំណង ឯករាជ្យភាព អំណាច តម្លាភាព និងកិច្ចសហប្រតិបត្តិការ

ប្រព័ន្ធត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាពត្រូវមានការទទួលខុសត្រូវ និងគោលបំណងច្បាស់លាស់សំរាប់អាជ្ញាធរនីមួយៗដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យធនាគារ ។ អាជ្ញាធរនីមួយៗត្រូវមានឯករាជ្យភាព ខាងផ្នែកប្រតិបត្តិការ ដំណើរការដោយតម្លាភាព អភិបាលកិច្ចល្អនិងធនធានគ្រប់គ្រាន់ និងទទួលខុសត្រូវរាល់ការបំពេញភារៈកិច្ចរបស់ខ្លួន ។ ក្របខ័ណ្ឌច្បាប់ដ៏សមស្របសំរាប់ការត្រួតពិនិត្យធនាគារជាការចាំបាច់ផងដែរ ដែលរួមមានការផ្តល់សិទ្ធិអំណាចក្នុងការបង្កើតធនាគារនិងការត្រួតពិនិត្យជាប្រចាំ សិទ្ធិអំណាចក្នុងការដាក់ទណ្ឌកម្មខាងវិន័យក្នុងករណីមិនគោរពតាមច្បាប់ និងបទប្បញ្ញត្តិដែលនាំឱ្យប៉ះពាល់ដល់ភាពរឹងមាំនិងសុវត្ថិភាពនិងការការពារតាមផ្លូវច្បាប់ដល់មន្រ្តីត្រួតពិនិត្យ ។ គោលការណ៍សំរាប់បែងចែកព័ត៌មានរវាងមន្រ្តីត្រួតពិនិត្យ និងការរក្សាការសំងាត់នៃព័ត៌មានទាំងនោះគួររៀបចំឱ្យមានឡើង ។

---

[៤] *បន្ថែមទៅលើគោលការណ៍ស្នូលទាំងនោះ នៅក្នុងឯកសារវិធីសាស្រ្តគោលការណ៍ស្នូល គណៈកម្មាធិការបាសែលបានបង្កើតឡើងនូវនីតិវិធីកាន់តែលំអិតសំរាប់វាយតំលៃពីភាពអនុលោមទៅតាមគោលការណ៍នីមួយៗ បោះផ្សាយដំបូងនៅក្នុងឆ្នាំ ១៩៩៩ និងបានធ្វើ បច្ចុប្បន្នកម្មដែល ជាផ្នែកមួយនៃការត្រួតពិនិត្យឡើងវិញ ។*

[៥] *និយមន័យ និងការពន្យល់បន្ថែមពីគោលការណ៍ទាំងនេះមាននៅក្នុងឯកសារ វិធីសាស្រ្តនៃគោលការណ៍ស្នូល ។*

**គោលការណ៍ទី ២ : សកម្មភាពដែលបានអនុញ្ញាត**

សកម្មភាពដែលបានអនុញ្ញាតចំពោះគ្រឹះស្ថានមានអាជ្ញាប័ណ្ណ ជាធនាគារដែលត្រូវទទួលរងការត្រួតពិនិត្យ ត្រូវតែបញ្ជាក់ឱ្យបានច្បាស់ ហើយការប្រើប្រាស់ពាក្យថា "ធនាគារ" ជានាមសញ្ញាត្រូវធ្វើការត្រួតពិនិត្យតាមដែលអាចធ្វើបាន ។

**គោលការណ៍ទី ៣ : លក្ខណៈវិនិច្ឆ័យនៃអាជ្ញាប័ណ្ណ**

អាជ្ញាធរផ្តល់អាជ្ញាប័ណ្ណត្រូវមានសិទ្ធិអំណាចក្នុងការបង្កើតលក្ខណៈវិនិច្ឆ័យ និងបដិសេធលើការដាក់ពាក្យសំរាប់ការបង្កើតដែលមិនសមស្របទៅនឹងស្តង់ដារដែលបានបង្កើត ។ ដំណើរការផ្តល់អាជ្ញាប័ណ្ណជាអប្បបរមា គួរតែមានការវាយតម្លៃពីរចនាសម្ព័ន្ធនៃម្ចាស់ភាគហ៊ុន អភិបាលកិច្ចរបស់ធនាគារ និងក្រុមសម្ព័ន្ធញាតិទាំងឡាយ ដូចជាភាពសមស្របនិងទ្រព្យសម្បត្តិនៃសមាជិកក្រុមប្រឹក្សាភិបាលនិងអ្នកគ្រប់គ្រងថ្នាក់ខ្ពស់ យុទ្ធសាស្ត្រ និង ផែនការប្រតិបត្តិការ ការត្រួតពិនិត្យផ្ទៃក្នុងនិងការគ្រប់គ្រងហានិភ័យ និងការព្យាករណ៍ស្ថានភាពហិរញ្ញវត្ថុ ដោយរួមបញ្ចូលទាំងដើមទុនមូលដ្ឋានផងដែរ ។ ប្រសិនបើភាគទុនិក ឬក្រុមហ៊ុនដែលដាក់ពាក្យសុំជាធនាគារបរទេស ការអនុញ្ញាតិជាមុនពីស្ថាប័នត្រួតពិនិត្យនៅប្រទេសដើមត្រូវយកមកពិចារណា ។

**គោលការណ៍ទី ៤ : ការផ្ទេរភាគហ៊ុនសំខាន់**

ភ្នាក់ងារត្រួតពិនិត្យត្រូវមានអំណាចក្នុងការពិនិត្យមើល និងបដិសេធចំពោះសំណើទាំងឡាយណាដែលធ្វើការផ្ទេរភាគហ៊ុនសំខាន់ ឬការគ្រប់គ្រងអត្ថប្រយោជន៍ដោយផ្ទាល់និងដោយប្រយោលនៅក្នុងធនាគារ ដែលមានស្រាប់ទៅភាគីផ្សេងទៀត ។

**គោលការណ៍ទី ៥ : ការកាន់កាប់ចំបងៗ**

ភ្នាក់ងារត្រួតពិនិត្យត្រូវមានសិទ្ធិអំណាចក្នុងការរៀបចំលក្ខខណ្ឌ ដើម្បីពិនិត្យមើលនូវការកាន់កាប់ចំបងៗ ឬការវិនិយោគដោយធនាគារ ដូចជាការបង្កើតប្រតិបត្តិការឆ្លងប្រទេស និងបញ្ជាក់ថាសាជីវកម្មសម្ព័ន្ធញាតិ ឬ សាជីវកម្មស្ថិតនៅក្រោមរចនាសម្ព័ន្ធមិនបានជំរុញឱ្យធនាគារទទួលរងហានិភ័យហួសកំណត់ ឬ រារាំងដល់ការត្រួតពិនិត្យដ៏មានប្រសិទ្ធភាពទេ។

**គោលការណ៍ទី ៦ : ភាពគ្រប់គ្រាន់នៃដើមទុន**

ភ្នាក់ងារត្រួតពិនិត្យត្រូវកំណត់ដោយប្រុងប្រយ័ត្ន និងសមស្របនូវភាពគ្រប់គ្រាន់នៃដើមទុនអប្បបរមា តម្រូវឱ្យធនាគារឆ្លុះបញ្ចាំងពីហានិភ័យដែលធនាគារទទួលយក និងត្រូវកំណត់សមាសធាតុនៃដើមទុនដោយត្រូវស្វែងយល់ពីលទ្ធភាពស្រូបយកការខាតបង់ ។ ចំពោះធនាគារដែលធ្វើប្រតិបត្តិការជាអន្តរជាតិ ការកំណត់តំរូវការទាំងនេះ យ៉ាងហោចណាស់មិនត្រូវតិចជាងអ្វីដែលបានបង្កើតឡើងនៅក្នុងតំរូវការបច្ចុប្បន្នរបស់បាសែលទេ។

**គោលការណ៍ទី ៧ : ដំណើរការគ្រប់គ្រងហានិភ័យ**

ភ្នាក់ងារត្រួតពិនិត្យត្រូវទទួលការបំពេញសេចក្តីត្រូវការថា ធនាគារនិងក្រុមសម្ព័ន្ធធនាគារមានរួចជាស្រេចនូវដំណើរការគ្រប់គ្រងហានិភ័យដ៏សមស្របមួយ (រួមទាំងការត្រួតពិនិត្យពីសំណាក់ក្រុមប្រឹក្សានិងអ្នកគ្រប់គ្រងជាន់ខ្ពស់) ក្នុងការកំណត់វាយតំលៃ ត្រួតពិនិត្យ និងតាមដាន ឬកាត់បន្ថយហានិភ័យសំខាន់ៗ និងដើម្បីប៉ាន់ប្រមាណពីភាពគ្រប់គ្រាន់

នៃដើមទុនទាំងមូលធៀបទៅនឹងប្រវត្តិហានិភ័យរបស់ពួកគេ ។ ដំណើរការនេះត្រូវស៊ីសង្វាក់ជាមួយនឹងទំហំ និងភាពស្មុគស្មាញរបស់ស្ថាប័ន ។

**គោលការណ៍ទី ៨ : ហានិភ័យឥណទាន**

ភ្នាក់ងារត្រួតពិនិត្យត្រូវទទួលការបំពេញសេចក្តីត្រូវការថា ធនាគារមានដំណើរការគ្រប់គ្រងហានិភ័យឥណទានដែលពិចារណាទៅលើប្រវត្តិហានិភ័យរបស់ស្ថាប័នជាមួយនឹងគោលនយោបាយ និងដំណើរការប្រុងប្រយ័ត្នដើម្បីកំណត់ វាស់វែង ត្រួតពិនិត្យ និងតាមដានហានិភ័យឥណទាន (រួមទាំងហានិភ័យសមាសភាគី) ។ ប្រការនេះ អាចរួមបញ្ចូលការផ្តល់ឥណទាន និងការវិនិយោគ ការវាយតម្លៃគុណភាពឥណទាននិងការវិនិយោគនោះ និង ការគ្រប់គ្រងជាប្រចាំលើសំពៀតវិនិយោគ ។

**គោលការណ៍ទី ៩ : ទ្រព្យសកម្មដែលមានបញ្ហា សំវិធានធន និងទុនបំរុង**

ភ្នាក់ងារត្រួតពិនិត្យត្រូវទទួលការបំពេញសេចក្តីត្រូវការថា ធនាគារបានបង្កើត និងប្រកាន់ខ្ជាប់នូវការអនុវត្តអនុលោមទៅតាមគោលនយោបាយ និងនីតិវិធីរបស់ខ្លួនដើម្បីគ្រប់គ្រងទ្រព្យសកម្មដែលមានបញ្ហា និងវាយតំលៃលើភាពគ្រប់គ្រាន់នៃសំវិធានធន និង ទុនបំរុង ។

**គោលការណ៍ទី ១០ : ការកំណត់ហានិភ័យធំៗ**

ភ្នាក់ងារត្រួតពិនិត្យត្រូវទទួលការបំពេញសេចក្តីត្រូវការថា ធនាគារមានគោលនយោបាយនិងនីតិវិធីដែលអាចឱ្យអ្នកគ្រប់គ្រងធ្វើការកំណត់ និងគ្រប់គ្រងការប្រមូលផ្តុំនៅក្នុងសំពៀតឥណទាន ហើយភ្នាក់ងារត្រួតពិនិត្យត្រូវកំណត់កំរិតជាបទបញ្ញាប្រុងប្រយ័ត្ន ដើម្បីរារាំងហានិភ័យធនាគារចំពោះសមាសភាគីតែមួយ ឬសមាសភាគី ច្រើនដែលមានទំនាក់ទំនងគ្នា ។

**គោលការណ៍ទី ១១ : ហានិភ័យឥណទានទៅសម្ព័ន្ធញាតិ**

ដើម្បីទប់ស្កាត់ផលលំបាកដែលកើតឡើងពីហានិភ័យឥណទានសម្ព័ន្ធញាតិ (ទាំងក្នុងតារាងតុល្យការ និង ក្រៅតារាងតុល្យការ) និងដើម្បីបង្ហាញពីទំនាស់ផលប្រយោជន៍ ភ្នាក់ងារត្រួតពិនិត្យត្រូវកំណត់ជាស្រេចនូវការតម្រូវនានា ដែលធនាគារអាចមានហានិភ័យជាមួយក្រុមហ៊ុនសម្ព័ន្ធញាតិនិងឯកត្តជននីមួយៗទៅតាមករណីជាក់ស្តែង ។ ហានិភ័យទាំងនេះត្រូវបានត្រួតពិនិត្យយ៉ាងមានប្រសិទ្ធភាព ។ ដំណាក់កាលសមស្របត្រូវបានអនុវត្តដើម្បីគ្រប់គ្រង និងកាត់បន្ថយហានិភ័យ ហើយការលុបចោលឥណទានសម្ព័ន្ធញាតិ ត្រូវធ្វើឡើងទៅតាមគោលការណ៍ និងដំណើរការជាស្តង់ដារ ។

**គោលការណ៍ទី ១២ : ហានិភ័យប្រទេស និងហានិភ័យនៃការផ្ទេរ**

ភ្នាក់ងារត្រួតពិនិត្យត្រូវទទួលការបំពេញសេចក្តីត្រូវការថា ធនាគារមានគោលនយោបាយនិងដំណើរការសមស្របសំរាប់កំណត់ វាស់វែង ត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យប្រទេសនិងហានិភ័យនៃការផ្ទេរនៅក្នុងការផ្តល់កម្ចី និងសកម្មភាពវិនិយោគជាអន្តរជាតិរបស់ខ្លួន និងសំរាប់រក្សាភាពគ្រប់គ្រាន់នៃសំវិធានធននិងទុនបំរុងចំពោះហានិភ័យទាំងនោះ ។

**គោលការណ៍ទី ១៣ : ហានិភ័យទីផ្សារ**

ភ្នាក់ងារត្រួតពិនិត្យត្រូវទទួលការបំពេញសេចក្តីត្រូវការថា ធនាគារមានគោលនយោបាយនិងនីតិវិធីដែលអាចកំណត់ វាស់វែង ត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យទីផ្សារអោយបានត្រឹមត្រូវ ។ ភ្នាក់ងារត្រួតពិនិត្យត្រូវមានសិទ្ធិអំណាច

ក្នុងការកំណត់កំរិតជាក់លាក់ និង/ឬ តំរូវការដើមទុនជាក់លាក់ចំពោះហានិភ័យទីផ្សារប្រសិនបើអាចធ្វើបាន ។

**គោលការណ៍ទី ១៤ : ហានិភ័យសាច់ប្រាក់ងាយស្រួល**

ភ្នាក់ងារត្រួតពិនិត្យត្រូវទទួលការបំពេញសេចក្ដីត្រូវការថា ធនាគារមានយុទ្ធសាស្ត្រគ្រប់គ្រងសាច់ប្រាក់ងាយស្រួល ដែលពិចារណាអំពីប្រវត្តិហានិភ័យរបស់ស្ថាប័ន ហើយមានគោលនយោបាយនិងនីតិវិធីប្រុងប្រយ័ត្ន ដើម្បីកំណត់ វាយតំលៃ ត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល និងដើម្បីគ្រប់គ្រងសាច់ប្រាក់ងាយស្រួលជាប្រចាំ ។ ភ្នាក់ងារត្រួតពិនិត្យតំរូវឱ្យធនាគារមានផែនការយថាហេតុសំរាប់ដោះស្រាយបញ្ហា សាច់ប្រាក់ងាយស្រួល ។

**គោលការណ៍ទី ១៥ : ហានិភ័យប្រតិបត្តិការ**

ភ្នាក់ងារត្រួតពិនិត្យត្រូវទទួលការបំពេញសេចក្ដីត្រូវការថា ធនាគារមានគោលនយោបាយនិងនីតិវិធីគ្រប់គ្រងហានិភ័យ ដើម្បីកំណត់ ប៉ាន់ប្រមាណ ត្រួតពិនិត្យ និងកាត់បន្ថយហានិភ័យប្រតិបត្តិការ ។ គោលនយោបាយនិងដំណើរការទាំងនោះត្រូវមានភាពសមស្របជាមួយនឹងទំហំ និងភាពស្មុគស្មាញរបស់ធនាគារ ។

**គោលការណ៍ទី ១៦ : ហានិភ័យអត្រាការប្រាក់**

ភ្នាក់ងារត្រួតពិនិត្យត្រូវទទួលការបំពេញសេចក្ដីត្រូវការថា ធនាគារមានប្រព័ន្ធដ៏មានប្រសិទ្ធភាពរួចជាស្រេច ដើម្បីកំណត់ វាស់វែង ត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យអត្រាការប្រាក់នៅក្នុងធនាគាររួមទាំងយុទ្ធសាស្ត្រ ដ៏ល្អដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងបានអនុវត្តដោយគណៈគ្រប់គ្រងជាន់ខ្ពស់ សមស្របទៅនឹង ទំហំ និងភាពស្មុគស្មាញនៃហានិភ័យនេះ ។

**គោលការណ៍ទី ១៧ : ការត្រួតពិនិត្យផ្ទៃក្នុងនិងសវនកម្ម**

ភ្នាក់ងារត្រួតពិនិត្យត្រូវទទួលការបំពេញសេចក្ដីត្រូវការថា ធនាគារមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរួចជាស្រេចដែលសមស្របទៅនឹងទំហំ និងភាពស្មុគស្មាញរបស់អាជីវកម្មធនាគារ ។ ការត្រួតពិនិត្យផ្ទៃក្នុងគួររួមបញ្ចូលការចាត់ចែងច្បាស់លាស់សំរាប់ផ្ដល់សិទ្ធិអំណាចនិងការទទួលខុសត្រូវ ការបែងចែកមុខងារដែលទាក់ទងជាមួយការប្រតិបត្តិរបស់ធនាគារ ការផ្ដល់មូលនិធិ ការចុះបញ្ជីគណនេយ្យសំរាប់ទ្រព្យសកម្មនិងទ្រព្យអកម្ម ការផ្ទៀងផ្ទាត់ដំណើរការទាំងនេះការការពារទ្រព្យសកម្ម របស់ធនាគារ និងឯករាជ្យភាពនៃការត្រួតពិនិត្យផ្ទៃក្នុង និងមុខងារអនុវត្តតាម ដើម្បីសាកល្បងពីការអនុវត្តត្រឹមត្រូវទៅតាមប្រព័ន្ធត្រួតពិនិត្យទាំងនោះ ក៏ដូចជាទៅតាមច្បាប់ និងបទប្បញ្ញត្តិ ដែលមានជាធរមាន ។

**គោលការណ៍ទី ១៨ : ការបំពានលើសេវាកម្មហិរញ្ញវត្ថុ**

ភ្នាក់ងារត្រួតពិនិត្យត្រូវបានទទួលការបំពេញសេចក្ដីត្រូវការថា ធនាគារមានគោលនយោបាយ និងនីតិវិធីគ្រប់គ្រាន់រួចជាស្រេចរាប់បញ្ចូលទាំងបញ្ញត្តិស្ដីពី "គោលការណ៍ស្គាល់អតិថិជន" ដែលជំរុញឱ្យមានក្រមសីលធម៌ និងស្តង់ដាវិជ្ជាជីវៈខ្ពស់ខាងវិស័យហិរញ្ញវត្ថុ និងទប់ស្កាត់មិនឱ្យមានសកម្មភាពឧក្រិដ្ឋកម្មឆ្លងកាត់ធនាគារ ទោះជាចេតនា ឬអចេតនាក៏ដោយ ។

**គោលការណ៍ទី ១៩ : វិធីត្រួតពិនិត្យ**

ប្រព័ន្ធត្រួតពិនិត្យធនាគារដ៏មានប្រសិទ្ធភាពតំរូវឱ្យភ្នាក់ងារត្រួតពិនិត្យ យល់ឱ្យច្បាស់នូវប្រតិបត្តិការរបស់ធនាគារនីមួយៗ ធនាគារជាក្រុម និងពីប្រព័ន្ធធនាគារទាំងមូលដោយផ្តោតលើសុវត្ថិភាពនិងភាពរឹងមាំ និង ស្ថិរភាពរបស់ប្រព័ន្ធធនាគារ ។

**គោលការណ៍ទី ២០ : បច្ចេកទេសត្រួតពិនិត្យ**

ប្រព័ន្ធត្រួតពិនិត្យធនាគារដ៏មានប្រសិទ្ធភាព តំរូវឱ្យមានការត្រួតពិនិត្យលើឯកសារនិងការត្រួតពិនិត្យដល់ទីកន្លែង និងត្រូវទាក់ទងជាប្រចាំជាមួយគណៈគ្រប់គ្រងធនាគារ ។

**គោលការណ៍ទី ២១ : របាយការណ៍ត្រួតពិនិត្យ**

ភ្នាក់ងារត្រួតពិនិត្យត្រូវមានមធ្យោបាយក្នុងការប្រមូលពិនិត្យឡើងវិញ និងវិភាគរបាយការណ៍ប្រុងប្រយ័ត្ន និងទិន្នន័យស្ថិតិពីធនាគារដោយឈរលើមូលដ្ឋានរួម និងដោយឡែក និងត្រូវមានមធ្យោបាយផ្ទៀងផ្ទាត់របាយការណ៍ទាំងនេះដោយឯករាជ្យតាមរយៈការចុះត្រួតពិនិត្យដល់ទីកន្លែង ឬ ការប្រើប្រាស់អ្នកជំនាញពីខាងក្រៅ ។

**គោលការណ៍ទី ២២ : គណនេយ្យកម្មនិងការបង្ហាញ**

ភ្នាក់ងារត្រួតពិនិត្យត្រូវទទួលការបំពេញសេចក្តីត្រូវការថា ធនាគារនីមួយៗបានរក្សាទុករបាយការណ៍គ្រប់គ្រាន់ដែលរៀបចំអនុលោមទៅតាមគោលការណ៍គណនេយ្យ និងការអនុវត្តដែលទទួលស្គាល់ដោយអន្តរជាតិ និងបោះផ្សាយជាប្រចាំនូវព័ត៌មានដែលឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវពីស្ថានភាពហិរញ្ញវត្ថុ និងប្រាក់ចំណេញរបស់ខ្លួន ។

**គោលការណ៍ទី ២៣ : សិទ្ធិអំណាចក្នុងការកែតំរូវរបស់ភ្នាក់ងារត្រួតពិនិត្យ**

ភ្នាក់ងារត្រួតពិនិត្យត្រូវមានឧបករណ៍សំរាប់ត្រួតពិនិត្យឱ្យបានគ្រប់គ្រាន់ ដើម្បីចាត់វិធានការកែតំរូវឱ្យទាន់ពេលវេលា ។ ឧបករណ៍ទាំងនេះរួមមាន សិទ្ធិដកហូតអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារ ឬ សមត្ថភាពផ្តល់អនុសាសន៍អំពីការដកហូតយកអាជ្ញាប័ណ្ណមកវិញប្រសិនបើអាចធ្វើបាន ។

**គោលការណ៍ទី ២៤ : ការត្រួតពិនិត្យប្រមូលផ្តុំ**

ធាតុសំខាន់មួយនៃការត្រួតពិនិត្យធនាគារតំរូវឱ្យភ្នាក់ងារត្រួតពិនិត្យ ធ្វើការត្រួតពិនិត្យក្រុមធនាគារ ដោយឈរលើមូលដ្ឋានប្រមូលផ្តុំ ធ្វើការតាមដានឱ្យបានគ្រប់គ្រាន់ ហើយប្រសិនបើអាចធ្វើបានត្រូវអនុវត្តបទដ្ឋានប្រុងប្រយ័ត្នចំពោះគ្រប់ប្រតិបត្តិការអាជីវកម្មរបស់ក្រុមធនាគារដែលធ្វើប្រតិបត្តិការទូទាំងពិភពលោក ។

**គោលការណ៍ទី ២៥ : ទំនាក់ទំនងរវាងភ្នាក់ងារត្រួតពិនិត្យក្នុងស្រុក និងភ្នាក់ងារក្រៅស្រុក**

ការត្រួតពិនិត្យប្រមូលផ្តុំឆ្លងប្រទេសតំរូវឱ្យមានកិច្ចសហប្រតិបត្តិការ និងផ្លាស់ប្តូរព័ត៌មានរវាងភ្នាក់ងារត្រួតពិនិត្យក្នុងស្រុកនិងភ្នាក់ងារត្រួតពិនិត្យផ្សេងៗទៀតដែលពាក់ព័ន្ធ ជាពិសេសភ្នាក់ងារត្រួតពិនិត្យក្រៅស្រុក ។ ភ្នាក់ងារត្រួតពិនិត្យ

ធនាគារត្រូវតែតំរូវឱ្យធនាគារបរទេសដែលធ្វើប្រតិបត្តិការក្នុងស្រុក អនុវត្តន៏តាមស្តង់ដារដែលបានដាក់ឱ្យគ្រឹះស្ថានក្នុងស្រុកអនុវត្តន៏ ។

៧. ទាក់ទងនឹងវិធីសាស្រ្តត្រួតពិនិត្យផ្សេងៗ គោលការណ៏ស្នូលនឹងមានលក្ខណៈអព្យាក្រឹត្យប្រសិនបើគោលដៅកែប្រែនានាត្រូវបានសំរេច ។ គោលការណ៏នានាមិនត្រូវបានរៀបចំឡើងដើម្បីបំពេញនូវគ្រប់សេចក្តីត្រូវការ និងកាលៈទេសៈនៃគ្រប់ប្រព័ន្ធធនាគារនោះទេ ។ ប៉ុន្តែ កាលៈទេសៈប្រទេសជាក់លាក់គួរតែត្រូវបានពិចារណាឱ្យបានសមស្របជាងនេះនៅក្នុងការវាយតំលៃ និងការចរចារគ្នារវាងអ្នកវាយតំលៃ និងអជ្ញាធរ របស់ប្រទេស។

៨. អាជ្ញាធរជាតិនានាគួរតែយកគោលការណ៏ទាំងនេះទៅអនុវត្តក្នុងការត្រួតពិនិត្យគ្រឹះស្ថានធនាគារទាំងអស់ ដែលស្ថិតនៅក្រោមអំណាចរបស់ខ្លួន [6] ។ ប្រទេសនិមួយៗជាពិសេសប្រទេសដែលមានទីផ្សារ និងស្ថាប័នដែលទំនើបអាចពង្រីកបន្ថែមគោលការណ៏ទាំងនេះដើម្បីសំរេចបាននូវការអនុវត្តការត្រួតពិនិត្យដ៏ប្រសើរបំផុត ។

៩. ក៏រិតនៃការគោរពបានខ្ពស់តាមគោលការណ៏នានានឹងជម្រុញឱ្យមានស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុទាំងមូល ។ ប៉ុន្តែនេះមិនធានាដូច្នេះទេ ហើយក៏នឹងមិនអាចទប់ស្កាត់ការដួលរលំរបស់ធនាគារនិមួយៗដែរ ។ ការត្រួតពិនិត្យធនាគារមិនអាច (និងមិនគួរ) ផ្តល់ការធានាថាធនាគារនឹងមិនដួលរលំនោះទេ ។ នៅក្នុងសេដ្ឋកិច្ចទីផ្សារ ការដួលរលំគឺជាផ្នែកមួយនៃការទទួលយកហានិភ័យ ។

១០. គណៈកម្មាធិការបានរៀបចំរួចជាស្រេចក្នុងការជំរុញការងារនៅថ្នាក់ជាតិ ដើម្បីអនុវត្តនូវគោលការណ៏ទាំងនេះ ជាមួយនឹងស្ថាប័នត្រួតពិនិត្យ និងភាគីពាក់ព័ន្ធផ្សេងទៀត ។ គណៈកម្មាធិការបានអញ្ជើញស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងភ្នាក់ងារផ្តល់ជំនួយនានាឱ្យប្រើនូវគោលការណ៏ទាំងនេះជួយឱ្យប្រទេសនីមួយៗ អាចពង្រឹងនូវការរៀបចំការត្រួតពិនិត្យរបស់ពួកគេ ។ គណៈកម្មាធិការនឹងបន្តកិច្ចសហការយ៉ាងជិតស្និទ្ធ ជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោកក្នុងការត្រួតពិនិត្យការអនុវត្តនូវបទដ្ឋានប្រុងប្រយ័ត្ន របស់គណៈកម្មាធិការ ។ គណៈកម្មាធិការក៏តាំងចិត្តផងដែរក្នុងការពង្រឹងបន្ថែមទៀតនូវទំនាក់ទំនងជាមួយ អ្នកត្រួតពិនិត្យមកពីបណ្តាប្រទេសមិននៅក្នុង G10 ។

## លក្ខខណ្ឌតម្រូវឱ្យមានជាមុនសំរាប់ការត្រួតពិនិត្យធនាគារដោយប្រសិទ្ធភាព

១១. ប្រព័ន្ធត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាពចាំបាច់ផ្អែកលើធាតុ ឬលក្ខខណ្ឌខាងក្រៅមួយចំនួន ។ លក្ខខណ្ឌទាំងនេះ ទោះបីភាគច្រើនស្ថិតនៅក្រៅអំណាចគ្រប់គ្រងផ្ទាល់របស់អ្នកត្រួតពិនិត្យក៏ដោយ ក៏មានឥទ្ធិពលទៅលើប្រសិទ្ធភាពនៃការត្រួតពិនិត្យជាក់ស្តែងដែរ ។ នៅពេលដែលមានកង្វះខាតកើតមានឡើង អ្នកត្រួតពិនិត្យគួរឱ្យរដ្ឋាភិបាលដឹងអំពី

---

[6] *នៅក្នុងប្រទេសដែលគ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារផ្តល់សេវាប្រាក់បញ្ញើ និងកំចីស្រដៀងគ្នានឹងសេវារបស់ធនាគារ គោលការណ៏មួយចំនួនធំដែលកំណត់នៅក្នុងឯកសារនេះក៏នឹងអាចយកមកប្រើប្រាស់ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារដែរ ។ ប៉ុន្តែក៏មានការទទួលស្គាល់ផងដែរថា ប្រភេទមួយចំនួននៃគ្រឹះស្ថាននេះអាចទទួលរងការដាក់បញ្ញត្តិខុសពីធនាគារ ប្រសិនបើចំណែកប្រាក់បញ្ញើរបស់គ្រឹះស្ថានទាំងនោះមិនមានចំនួនធំនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុនោះទេ ។*

កង្វះខាតទាំងនេះ និងលទ្ធផលអវិជ្ជមានដែលកើតមានឡើង និងដែលអាចនឹងកើតមានឡើងទៅលើកម្មវត្ថុនៃការត្រួតពិនិត្យ ។ ជាផ្នែកមួយនៃជំនួញធម្មតា អ្នកត្រួតពិនិត្យគួរតែឆ្លើយតបក្នុងគោលដៅកាត់បន្ថយនូវឥទ្ធិពលនៃកង្វះខាតទាំងនេះទៅលើប្រសិទ្ធភាពនៃបទបញ្ញត្តិ និងការត្រួតពិនិត្យធនាគារ ។ ធាតុខាងក្រៅទាំងនេះរួមមាន :

- គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដែលរឹងមាំ និងមាននិរន្តរភាព
- ហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលជឿនលឿន
- គោលការណ៍ទីផ្សារដែលមានប្រសិទ្ធភាព និង
- យន្តការផ្តល់ការការពារប្រព័ន្ធក្នុងកំរិតសមស្របមួយ (ឬសំណាញ់សុវត្ថិភាពសាធារណៈ)

១២. គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏រឹងមាំគឺជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធហិរញ្ញវត្ថុដែលមានស្ថិរភាព ។ រឿងនេះមិនមែនស្ថិតនៅក្នុងដែនសមត្ថភាពរបស់អ្នកត្រួតពិនិត្យធនាគារទេ ។ ប៉ុន្តែអ្នកត្រួតពិនិត្យចាំបាច់ត្រូវធ្វើអន្តរាគមន៍ប្រសិនបើពួកគេយល់ថាគោលនយោបាយដែលអនុវត្តកំពុងតែធ្វើឱ្យសុវត្ថិភាព និងភាពរឹងមាំ នៃប្រព័ន្ធធនាគារចុះខ្សោយ ។

១៣. ហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលជឿនលឿនមួយចាំបាច់ត្រូវមានធាតុទាំងឡាយដូចខាងក្រោមនេះ ដែលប្រសិនបើមិនត្រូវបានគេផ្តល់ឱ្យគ្រប់គ្រាន់ទេនោះនឹងអាចនាំទៅរកភាពទន់ខ្សោយនៃប្រព័ន្ធ និងទីផ្សារហិរញ្ញវត្ថុ ឬក៏រារាំងនូវការអភិវឌ្ឍរបស់ប្រព័ន្ធ និងទីផ្សារហិរញ្ញវត្ថុទាំងនោះ ។

- ប្រព័ន្ធច្បាប់ពាណិជ្ជកម្មដែលរួមមានច្បាប់សាជីវកម្ម ច្បាប់ក្ស័យធន ច្បាប់កិច្ចសន្យា ច្បាប់ការពារ អ្នកប្រើប្រាស់ និងច្បាប់ទ្រព្យសម្បត្តិឯកជន ដែលត្រូវបានអនុវត្តឥតឈប់ឈរ និងផ្តល់នូវយន្តការដោះស្រាយជំលោះដ៏យុត្តិធម៌មួយ ។
- គោលការណ៍ និងច្បាប់គណនេយ្យដែលត្រូវបានគេកំណត់និយមន័យយ៉ាងច្បាស់លាស់ និងមានគ្រប់ស្ថានភាពនៃប្រតិបត្តិការ ព្រមទាំងមានការទទួលការយល់ស្របជាទូទៅពីអន្តរជាតិ ។
- ប្រព័ន្ធសវនកម្មឯករាជ្យសំរាប់ក្រុមហ៊ុនដែលមានទំហំធំ ដើម្បីធានាថាអ្នកប្រើប្រាស់នូវរបាយការណ៍ហិរញ្ញវត្ថុនានា ដែលរួមមានធនាគារផងដែរនោះ ទទួលបានការធានាដោយឯករាជ្យថាគណនីនានា អាចផ្តល់នូវទិដ្ឋភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបានយ៉ាងត្រឹមត្រូវនិងឥតលំអៀង ហើយគណនីទាំងនោះ ត្រូវបានរៀបចំឡើងដោយយោងទៅតាមគោលការណ៍គណនេយ្យដែលបានបង្កើតឡើង និងសវនករ ជាអ្នកទទួលខុសត្រូវលើការងារនេះ ។
- ប្រព័ន្ធតុលាការដែលមានប្រសិទ្ធភាព និងឯករាជ្យភាព ព្រមទាំងអ្នកអាជីពខាងគណនេយ្យ សវនកម្ម និងខាងច្បាប់ដែលស្ថិតនៅក្រោមច្បាប់ត្រឹមត្រូវ ។
- ច្បាប់គ្រប់គ្រងដែលមានការកំណត់យ៉ាងល្អ និងការត្រួតពិនិត្យគ្រប់គ្រាន់ ទៅលើទីផ្សារហិរញ្ញវត្ថុដទៃទៀត និងអ្នកចូលរួមក្នុងទីផ្សារទាំងនោះ ។ និង
- ប្រព័ន្ធទូទាត់ និងផាត់ទាត់ដែលមានសុវត្ថិភាព និងប្រសិទ្ធភាពសំរាប់ការទូទាត់នូវប្រតិបត្តិការហិរញ្ញវត្ថុនានាដែលហានិភ័យរបស់ដៃគូពាណិជ្ជកម្មត្រូវបានគ្រប់គ្រង ។

១៤. គោលការណ៍ទីផ្សារមានប្រសិទ្ធភាពពឹងផ្អែកមួយផ្នែកទៅលើ លំហូរព័ត៌មានគ្រប់គ្រាន់ដល់អ្នកចូលរួមក្នុងទីផ្សារ ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុដល់គ្រឹះស្ថានដែលគ្រប់គ្រងបានល្អ និងការរៀបចំផែនការនានា ដើម្បីធានាថាការសំរេចចិត្តរបស់វិនិយោគិននានាមិនត្រូវបានធ្វើឡើងដោយគ្មានព័ត៌មានគ្រប់គ្រាន់នោះទេ ។ ក្នុងចំណោមបញ្ហាដែលត្រូវដោះស្រាយទាំងនេះរួមមាន អភិបាលកិច្ច និងដើម្បីធានាថា ព័ត៌មានដែលផ្តល់ដោយ អ្នកសុំខ្ចីប្រាក់ចំពោះអ្នកវិនិយោគនិងម្ចាស់បំណុលពិតជាត្រឹមត្រូវ មានខ្លឹមសារ មានតម្លាភាព និងទាន់ពេលវេលា ។ សញ្ញារបស់ទីផ្សារអាចមានការភ័ណ្ឌច្រលំ និងវិន័យទីផ្សារអាចចុះខ្សោយ ប្រសិនបើរដ្ឋាភិបាលចង់ដាក់ឥទ្ធិពល ឬ យកប្រៀបលើការសំរេចចិត្តខាងពាណិជ្ជកម្ម ជាពិសេសការសំរេចចិត្តចំពោះការផ្តល់ឥណទាន ដើម្បីសំរេចតាមគោលនយោបាយសាធារណៈរបស់ខ្លួន ។ ក្នុងស្ថានភាពនេះវាមានសារសំខាន់ប្រសិនបើមានការធានាលើការផ្តល់ឥណទាន ហើយការធានាត្រូវបង្ហាញឱ្យដឹងជាសាធារណៈ ព្រមទាំងផែនការផ្សេងៗត្រូវធ្វើ ដើម្បីទូទាត់ឱ្យគ្រឹះស្ថានហិរញ្ញវត្ថុនៅពេលដែលឥណទានជាគោលនយោបាយត្រូវបានផ្អាកដំណើរការ ។

១៥. ជារួម ការសំរេចចិត្តទៅលើការការពារហានិភ័យជាប្រព័ន្ធក្នុងករិតសមស្របគឺជាបញ្ហាគោលនយោបាយ ដែលត្រូវលើកឡើងដោយអាជ្ញាធរពាក់ព័ន្ធ (ដោយរាប់បញ្ចូលទាំងធនាគារកណ្តាល) ជាពិសេសប្រសិនបើវាពាក់ព័ន្ធនឹងមូលនិធិសាធារណៈ ។ ជាធម្មតាអ្នកត្រួតពិនិត្យជាអ្នកដើរតួនាទីក្នុងករណីនេះ ព្រោះពួកគេមានការយល់ដឹងច្រើនលើស្ថាប័នពាក់ព័ន្ធ ។ វាមានសារសំខាន់ក្នុងការបែងចែកនូវភាពខុសគ្នាឱ្យបានច្បាស់រវាងតួនាទីការពារជាប្រព័ន្ធ (ឬសំណាញ់សុវត្ថិភាព) និងការត្រួតពិនិត្យជាប្រចាំថ្ងៃលើគ្រឹះស្ថានមានសាធនភាពគ្រប់គ្រាន់ ។ ក្នុងការដោះស្រាយនូវហានិភ័យជាប្រព័ន្ធទាំងនេះ ចាំបាច់ត្រូវកំណត់នូវហានិភ័យដែលនាំឱ្យប៉ះពាល់ដល់ទំនុកចិត្តទៅលើប្រព័ន្ធហិរញ្ញវត្ថុ និងហានិភ័យនៃការរីកដាលទៅដល់គ្រឹះស្ថានរឹងមាំដទៃទៀត និងមួយផ្នែកទៀត ចាំបាច់ត្រូវធ្វើការកាត់បន្ថយនូវការយល់ច្រឡំនូវសញ្ញាទីផ្សារ និងវិន័យទីផ្សារមានករិតទាបបំផុត[៧] ។ ក្នុងប្រទេសជាច្រើន ក្របខ័ណ្ឌនៃការការពារហានិភ័យជាប្រព័ន្ធរាប់បញ្ចូលនូវប្រព័ន្ធធានារ៉ាប់រងលើប្រាក់បញ្ញើ ។ ប្រសិនបើប្រព័ន្ធនេះត្រូវបានរៀបចំឡើងដោយប្រុងប្រយ័ត្ន ដើម្បីដាក់ករិតលើហានិភ័យក្រោយពេលផ្តល់ឥណទាន (Moral Hazard) វាអាចចូលរួមចំណែកបង្កើនទំនុកចិត្តសាធារណៈទៅលើប្រព័ន្ធនេះ ហើយជាលទ្ធផលអាច ដាក់ករិតដល់ការរាលដាលដែលកើតមានឡើងនៅពេលធនាគារកើតមានចលាចល ។

---

[7] *មើល BCBS សេចក្តីណែនាំពីការត្រួតពិនិត្យ ស្តីពីការចាត់វិធានការចំពោះធនាគារខ្សោយ ខែមីនា ឆ្នាំ២០០២*

# ឧបសម្ព័ន្ធទី ៦
# ប្រតិបត្តិការធនាគារដោយអេឡិចត្រូនិក

## ១. សេចក្ដីផ្ដើម

នៅក្នុងកំឡុងទស្សវត្សន៍ឆ្នាំ ១៩៦០ ធនាគារអាមេរិកបានចេញសេវាឆាប់រហ័សមួយដល់អតិថិជនរបស់ពួកគេ ដោយការប្រើប្រាស់ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិអេធីអ៊ឹម (ATM: Automatic Teller Machine) ។ នៅពេលនោះ គ្មានអតិថិជនណាម្នាក់ចង់ប្រើប្រាស់សេវានោះទេ ពីព្រោះម៉ាស៊ីនគ្មានភាពកក់ក្ដៅ និងគ្មានភាពស្និទ្ធស្នាលដូចបេឡាករឡើយ ។

ទោះជាយ៉ាងណាក៏ដោយ បច្ចុប្បន្ននេះស្ទើរតែគ្រប់គ្នាប្រើប្រាស់ម៉ាស៊ីនអេធីអ៊ឹម ដើម្បីដកសាច់ប្រាក់ ដាក់សាច់ប្រាក់ ឬផ្ទេរប្រាក់ ។ មានផលិតផល និងសេវាធនាគារជាច្រើនដែលកំពុងតែប្រែក្លាយទៅជាមានភាពងាយស្រួលប្រើប្រាស់ដល់មនុស្សដែលពុំសូវមានពេលគ្រប់គ្រាន់ទៅធនាគារ ដោយតំរង់ជួរជាបន្ទាត់រង់ចាំជួបបេឡា ។

ប្រតិបត្តិការធនាគារចល័ត អនុញ្ញាតឱ្យម្ចាស់គណនីពិនិត្យមើលសមតុល្យ ផ្ទេរប្រាក់ ស្ដាប់ប្រតិបត្តិការចាស់ និងធ្វើប្រតិបត្តិការធនាគារផ្សេងទៀត ។ អតិថិជនរបស់ធនាគារអាចធ្វើប្រតិបត្តិការទាំងនេះបន្ទាប់ពីធនាគារបិទ និងក្នុងពេលចុងសប្ដាហ៍ ។ ប្រតិបត្តិការធនាគារតាម Online ផ្ដល់ដល់អតិថិជននូវសេវាដូចសេវាប្រតិបត្តិការធនាគារចល័តដែរ ដោយប្រើប្រាស់កម្មវិធីសំរាប់អ៊ីនធឺណែត (Internet Browser) ។ ប្រតិបត្តិការធនាគារដោយអេឡិចត្រូនិក ឬ អី-បែងឃីញ ដំណើរការទៅបានដោយមិនចាំបាច់មានសាច់ប្រាក់ ឬមូលប្បទានប័ត្រឡើយ[១] ។

ដូច្នេះប្រតិបត្តិការធនាគារដោយអេឡិចត្រូនិក គឺជាការផ្ដល់សេវា និងផលិតផលធនាគារដល់អតិថិជនតាមរយៈមធ្យោបាយ ឬឧបករណ៍អេឡិចត្រូនិក ។

## ២. ការប្រើប្រាស់ប្រតិបត្តិការធនាគារដោយអេឡិចត្រូនិក

ថ្មីៗនេះគ្រឹះស្ថានធនាគារជាច្រើនមានគេហទំព័រផ្ទាល់ខ្លួនរបស់ពួកគេ ដែលប្រើសំរាប់ផ្ដល់ព័ត៌មានអំពីធនាគារ និងផលិតផលរបស់ពួកគេ ។ គេហទំព័ររបស់ពួកគេ ភាគច្រើនគឺប្រមូលផ្ដុំនូវព័ត៌មានផលិតផល និងសុន្ទរកថាទាក់ទងទៅនឹងសកម្មភាពអាជីវកម្មរបស់ពួកគេ ។ ទោះជាយ៉ាងណាក៏ដោយ ថ្មីៗនេះធនាគារទាំងតូចទាំងធំ នៅប្រទេសអភិវឌ្ឍន៍ជាច្រើនមានបទពិសោធន៍អំពីការប្រើប្រាស់អ៊ីនធឺណែត ជាមធ្យោបាយផ្គត់ផ្គង់សេវាធនាគារដោយអេឡិចត្រូនិក ។

មានទម្រង់នៃសេវាធនាគារដោយអេឡិចត្រូនិកជាច្រើន ដែលផ្គត់ផ្គង់ដោយធនាគារពាណិជ្ជដើម្បីសម្រួលដល់សេវាធនាគាររបស់ពួកគេ មានដូចជាម៉ាស៊ីនអេធីអ៊ឹម (ATM) ប្រតិបត្តិការធនាគារចល័ត (Mobile Banking) ប្រតិបត្តិការធនាគារតាមអ៊ីនធឺណែត (Internet Banking) ម៉ាស៊ីនឆូតកាត (POS: Point of Sale) ជាដើម ។

---

[1] *Barbara and Christopher A. Warnasch, Fluently English, The Evolution of electronic banking*

## ក. ម៉ាស៊ីនអេធីអ៊ឹម (Automatic Teller Machine)

ម៉ាស៊ីនអេធីអ៊ឹមត្រូវបានរៀបចំឡើងដើម្បីបំរើឱ្យមុខងារសំខាន់ៗរបស់ធនាគារ ។ វាដំណើរការទៅបានដោយសារប័ណ្ណប្លាស្ទិកដែលមានលក្ខណៈពិសេសរបស់វា[២] ។ ម៉ាស៊ីនអេធីអ៊ឹមអនុញ្ញាតឱ្យអតិថិជន ឬម្ចាស់ប័ណ្ណដកសាច់ប្រាក់ ដាក់សាច់ប្រាក់ ផ្ទេរប្រាក់ មើលសមតុល្យបាន ២៤ម៉ោងក្នុងមួយថ្ងៃ និង ៧ថ្ងៃក្នុងមួយសប្តាហ៍ ។ ដើម្បីប្រើប្រាស់សេវានេះជាដំបូង ម្ចាស់ប័ណ្ណត្រូវបញ្ចូលប័ណ្ណអេធីអ៊ឹម និងវាយបញ្ចូលលេខអត្តសញ្ញាណផ្ទាល់ខ្លួន (PIN) ។ ជំហ៊ានបន្ទាប់ ម្ចាស់ប័ណ្ណត្រូវ ជ្រើសរើសសេវាណាមួយដែលត្រូវប្រើ ។ ជំហ៊ានចុងក្រោយ ពេលដែលប្រតិបត្តិការចប់ម៉ាស៊ីនអេធីអ៊ឹមនឹងបញ្ចេញប័ណ្ណអេធីអ៊ឹមរបស់អ្នកមកក្រៅវិញ បន្ទាប់មកម្ចាស់ប័ណ្ណត្រូវដកប័ណ្ណនោះវិញភ្លាម ។ ម៉ាស៊ីនអេធីអ៊ឹមអាចផ្តល់ព័ត៌មានអំពីគណនីអតិថិជន និង អាចទទួលឃ្លាបញ្ជោផ្សេងៗអំពីអតិថិជនផងដែរ ។

នៅឆ្នាំ ២០០៧ មានម៉ាស៊ីនអេធីអ៊ឹមសរុបចំនួន ១៧៧ម៉ាស៊ីន ត្រូវបានតម្លើងនៅទូទាំងប្រទេសកម្ពុជា ដោយធនាគារពាណិជ្ជចំនួន ១០ ។ ភាគច្រើននៃម៉ាស៊ីនទាំងនោះត្រូវបានតម្លើងនៅរាជធានីភ្នំពេញ ទីរួមខេត្ត និងទីប្រជុំជន ។ បើប្រៀបធៀបទៅឆ្នាំ ២០០៦ ចំនួនម៉ាស៊ីនអេធីអ៊ឹមទាំងនេះបានកើនឡើងដល់ទៅ ១០៥% ។

## ខ. ម៉ាស៊ីនឆូតកាត (Point of Sale terminal)

ម៉ាស៊ីនឆូតកាត POS គឺជាទម្រង់មួយនៃប្រតិបត្តិការអេឡិចត្រូនិក ត្រូវបានប្រើប្រាស់ដើម្បីទូទាត់ពេលទិញទំនិញដោយប្រើប្រាស់ប័ណ្ណឥណពន្ធ (អាចជាប័ណ្ណអេធីអ៊ឹម) ឬប័ណ្ណឥណទាន ។ ដំណើរការនៃការទូទាត់ទាំងនេះគឺផ្ទេរប្រាក់ភ្លាមៗពីគណនីរបស់អ្នកទិញ ទៅគណនីរបស់អ្នកលក់ (ឬម្ចាស់ហាង) ។

ម៉ាស៊ីនឆូតកាតកំពុងកើនឡើងយ៉ាងខ្លាំងនៅក្នុងសកលលោកនេះ ។ នៅប្រទេសកម្ពុជានាកំឡុងឆ្នាំ ២០០៦ និង ២០០៧ ចំនួនម៉ាស៊ីនឆូតកាតទាំងនោះបានកើនឡើងរហូតដល់ចំនួន ១.៦៦៧ ម៉ាស៊ីន ដោយធនាគារពាណិជ្ជចំនួន ៦ ។ ភាគច្រើននៃទីតាំងម៉ាស៊ីនឆូតកាតទាំងនេះត្រូវបានតម្លើងនៅតាមផ្សារទំនើប ភោជនីយដ្ឋាន សណ្ឋាគារ និងស្ថានីយ៍ចាក់ប្រេង ។

## គ. ប្រតិបត្តិការធនាគារចល័ត (Mobile Banking)

ប្រតិបត្តិការធនាគារចល័តគឺជាប្រភេទសេវាមួយប្រើសំរាប់មើលសមតុល្យគណនី ធ្វើប្រតិបត្តិការធនាគារ និងការទូទាត់ជាដើម តាមរយៈឧបករណ៍អេឡិចត្រូនិកចល័តមួយ ដូចជាទូរស័ព្ទចល័តជាដើម ។ ភាគច្រើននៃប្រតិបត្តិការធនាគារចល័តបច្ចុប្បន្នធ្វើឡើងតាមរយៈការផ្ញើសារខ្លីៗ (SMS) ឬអ៊ិនធឺណែតចល័ត ប៉ុន្តែក៏អាចប្រើប្រាស់កម្មវិធីពិសេសណាមួយដែលបានទាញយក (Download) និងបញ្ចូលក្នុងឧបករណ៍ចល័តនោះបានដែរ[៣] ។ បច្ចុប្បន្នទោះបីជាក្រុមហ៊ុនទូរស័ព្ទចល័តកំពុងតែកើនឡើង និងប្រជែងគ្នានៅក្នុងទីផ្សារកម្ពុជាយ៉ាងណាក៏ដោយ ក៏ពុំទាន់មានធនាគារ និងក្រុមហ៊ុនក្នុងស្រុកទាំងនោះណាមួយ សហការគ្នាផ្តល់សេវាបែបនេះនៅឡើយទេ ។

---

[2] *e-banking, http://www.worlddjute.com/ebank.html, retrieved on March 03, 2008*
[3] *Mobile Banking, http://en.wikipedia.org/wiki/Mobile_banking.thml, retrieved on 4/02/08*

**ឃ. ប្រតិបត្តិការធនាគារអនឡាញ (Online Banking)**

ប្រតិបត្តិការធនាគារអនឡាញ ផ្តល់ដល់អតិថិជននូវសេវាធនាគារដូចគ្នាទៅនឹងទំរង់នៃប្រតិបត្តិការធនាគារដោយអេឡិចត្រូនិកផ្សេងទៀតដែរ ។ ប្រតិបត្តិការធនាគារតាមអ៊ិនធឺណែត ប្រើប្រាស់កម្មវិធីសំរាប់អ៊ិនធឺណែត (Web browser) ដែលមានសុវត្ថិភាពខ្ពស់ រួមមានកម្មវិធី Netscape Navigator ឬ Internet Explorer ។ កម្មវិធីសំរាប់អ៊ីនធឺណែតទាំងនេះអនុញ្ញាតឱ្យអតិថិជនរបស់ធនាគារចូលទៅដល់ព័ត៌មានស្តីពីគណនីរបស់ពួកគេ តាមរយៈគេហទំព័រនៃធនាគាររបស់ពួកគេ ពីគ្រប់ទីកន្លែង និងគ្រប់ពេលវេលា ។ សេវាខាងក្រោមនេះភាគច្រើនមាននៅក្នុងប្រតិបត្តិការតាមអ៊ីនធឺណែត រួមមានការពិនិត្យមើលសមតុល្យ មើលប្រតិបត្តិការចាស់ៗ ផ្ទេរប្រាក់រវាងគណនីដែលបានភ្ជាប់ និងស្នើរសុំរបាយការណ៍គណនីជាដើម ។

ធនាគារភាគច្រើននៅប្រទេសកម្ពុជាបានបង្កើតគេហទំព័រផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីផ្តល់ព័ត៌មានអំពីផលិតផល និងសេវាធនាគាររបស់ពួកគេ ។ លើសពីនេះទៅទៀតមានតែធនាគារក្នុងស្រុក អេ អិន ហ្សិត រ៉ូយ៉ាល់ មួយទេដែលបានផ្តល់សេវាធនាគារតាមអ៊ីនធឺណែតតាំងពីឆ្នាំ ២០០៥ មក ។

## ៣. អ៊ីនធឺណែត និងសុវត្ថិភាពទិន្នន័យ

កង្វល់ដែលបានកើតឡើងចំពោះធនាគារ ដែលបានផ្តល់ប្រតិបត្តិការធនាគារដោយអេឡិចត្រូនិក គឺសន្តិសុខ និងសុវត្ថិភាពទិន្នន័យនៅលើបណ្តាញអ៊ីនធឺណែតទាំងមូល ។ ជាការពិត វាគួរតែត្រូវបានលើកមកជជែកគ្នា ចំពោះប្រតិបត្តិការធនាគារអនឡាញ អំពីការរីកចំរើនដោយសន្ទឹមៗ ។ តើមកពីហេតុអ្វី? ចំលើយព្រោះមកពីគ្រឹះស្ថានហិរញ្ញវត្ថុទាំងនោះបានទទឹងរង់ចាំដំណោះស្រាយ ដូចជាសុវត្ថិភាពព័ត៌មានត្រូវបានលើកឡើងនិងបកស្រាយយ៉ាងច្បាស់ និងចំណាយថ្លៃដើមទាបក្នុងការរៀបចំប្រព័ន្ធទាំងមូល[៤] ។

ទោះជាយ៉ាងនេះក្តី មានធនាគារពាណិជ្ជភាគច្រើននៅក្នុងប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍បានផ្តល់ផលិតផល និង សេវាប្រតិបត្តិការធនាគារដោយអេឡិចត្រូនិក រួមមានម៉ាស៊ីនអេធីអ៊ឹម ម៉ាស៊ីនឆូតកាត និងការផ្ទេរប្រាក់ដោយប្រព័ន្ធអេឡិចត្រូនិកផ្សេងទៀត ។

ដើម្បីធានាសុវត្ថិភាពក្នុងការប្រើប្រាស់ប្រតិបត្តិការធនាគារដោយអេឡិចត្រូនិក អតិថិជនទាំងអស់មិនត្រូវចែកចាយព័ត៌មានផ្ទាល់ខ្លួន ដូចជាលេខ PIN ឬលេខសម្ងាត់ទៅដល់អ្នកណាម្នាក់ឡើយ រួមទាំងបុគ្គលិករបស់ធនាគារផង ។

## ៤. សរុបសេចក្តី

ប្រតិបត្តិការធនាគារដោយអេឡិចត្រូនិកត្រូវបានណែនាំឱ្យប្រើប្រាស់តាំងពីទសវត្សន៍ឆ្នាំ ១៩៦០ ដោយធនាគារនៅសហរដ្ឋអាមេរិក ។ ម៉ាស៊ីនអេធីអ៊ឹម ម៉ាស៊ីនឆូតកាត ប្រតិបត្តិការធនាគារចល័ត ប្រតិបត្តិការធនាគារតាមអ៊ិនធឺណែត

---

[4] *Brain Nixon and Mary Dixon (2000),* *SAMS Teach Yourself Today e-banking*

ទាំងនេះគឺជាឧទាហរណ៏នៃផលិតផល និងសេវាប្រតិបត្តិការធនាគារដោយអេឡិចត្រូនិក ។ បញ្ហាសុវត្ថិភាពទិន្ន័យក៏នៅតែជាការបារម្ភចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងអតិថិជនដែលប្រើប្រាស់សេវាអេឡិចត្រូនិកទាំងនោះ។ ខណៈដែលប្រតិបត្តិការអេឡិចត្រូនិកអាចផ្តល់អត្ថប្រយោជន៏ជាច្រើនដល់អតិថិជន និងឱកាសអាជីវកម្មថ្មីៗសំរាប់ធនាគារ[5] វាក៏ជាឧបសគ្គថ្មីៗសំរាប់ធនាគារខ្លួនឯង និង អាជ្ញាធររៀបចំបទបញ្ញត្តិធនាគារផងដែរ ។

[5] *IMF Policy Discussion Paper on Issues in Electronic Banking by Andrea Scheachter, March 2002*